# ព្រឹត្តិបត្រមេធាវី

# លេខ ២៤

# ខែ មករា-មីនា ឆ្នាំ ២០២០

រក្សាសិទ្ធិ © 2020 គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

មតិដែលសំដែងនៅក្នុងព្រឹត្តិបត្រនេះ គឺជាមតិរបស់អ្នកនិពន្ធផ្ទាល់ ហើយមិនឆ្លុះបញ្ចាំងនូវទស្សនៈរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាឡើយ។

ស្របតាមគោលការណ៍សេរីភាព នៃការបញ្ចេញមតិ ដែលជាគោលការណ៍គ្រឹះ និងមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គណៈមេធាវីគាំទ្រឱ្យមានភាពចម្រុះនៃមតិនានា។

សូមរក្សាសិទ្ធិ © ដោយអនុលោមតាមច្បាប់ស្តីពី “សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល” ដែលត្រូវបានប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៣ ហើយរាល់ការថតចម្លងឡើងវិញ ដោយគ្មានការអនុញ្ញាតពីគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាត្រូវហាមឃាត់។

ទំព័រ

# មាតិកា

សាររបស់ប្រធានគណៈមេធាវី ............ V

## ព្រហ្មទណ្ឌ

**បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ** ............ 1
១. សេចក្តីផ្តើម ............ 1
២.ខ្លឹមសារ ............ 1
២.១. ភាពខុសគ្នារវាង បទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មសង្គ្រាម និង បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ............ 1
២.២. បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ............ 3
២.២.១. ខ្លឹមសារ ............ 3
២.២.២. ធាតុផ្សំ ដែលព្រះរាជអាជ្ញាត្រូវបង្ហាញ ............ 4
៣. សង្ខេប ............ 5
៤. តារាងប្រៀបធៀបបទប្បញ្ញត្តិ ............ 6
**ការបញ្ឈប់ ឃាត់ខ្លួន និងឆែកឆេរ** ............ 9
១.សេចក្តីផ្តើម ............ 9
២. ខ្លឹមសារ ............ 9
២.១. ភាពខុសគ្នានៃកម្រិតភស្តុតាង ............ 9
២.២. ការសង្ស័យមានហេតុផល និង Probable Cause (PC) ............ 10
២.៣. ទណ្ឌកម្មនៃការមិនគោរពវិធាន ............ 13
៣. សង្ខេប ............ 13
**បទល្មើសរំលោភសេពសន្ថវៈ** ............ 15
១. សេចក្តីផ្តើម ............ 15
២. ខ្លឹមសារ ............ 15
២.១. អត្ថបទច្បាប់ ............ 15

២.២. ធាតុផ្សំនៃបទល្មើស...16
៣. ច្បាប់ យុត្តិសាស្ត្របរទេស និង យោបល់អ្នកជំនាញ...18
៤. សង្ខេប...21

**ច្បាប់ បរធនបាលកិច្ចនៅកម្ពុជា**

**ច្បាប់ បរធនបាលកិច្ចនៅកម្ពុជា**68F...25
១. គោលការណ៍ទូទៅ...25
១.១. និយមន័យ...25
១.២. គោលបំណង...25
១.៣. ដំណើរការអនុម័ត និងភាពចាំបាច់...25
២.រចនាសម្ព័ន្ធ...27
២.១. ជំពូកទី១ បទប្បញ្ញត្តិទូទៅ...27
២.២. ជំពូកទី២ បរធនបាលកិច្ច...27
២.៣. ជំពូកទី៣ បរធនបាលទាយក បរធនបាល អត្ថគាហកៈ...28
២.៤. ជំពូកទី៤ ការចុះបញ្ជីបរធនបាល ការត្រួតពិនិត្យ និងការបញ្ចប់បរធនបាល...29
២.៥. ជំពូកទី៥ ការដោះស្រាយវិវាទ និងការចុះអធិការកិច្ច...29
២.៦. ជំពូកទី៦ ទោសប្បញ្ញត្តិ...30
២.៧. ជំពូកទី៧ អន្តរប្បញ្ញត្តិ...30
២.៨. ជំពូកទី៨ អវសានប្បញ្ញត្តិ...30
៣. បទពិសោធន៍ និងការអនុវត្តនៅបរទេស...31
៣.១. ការអនុវត្តនៅបណ្តាប្រទេសប្រើប្រព័ន្ធច្បាប់ Common Law...31
៣.២. ការអនុវត្តនៅបណ្តាប្រទេសប្រើប្រព័ន្ធច្បាប់ Civil Law...31
៤. ការសន្និដ្ឋាន...32

# ប្រធានសក្តិ នៅក្នុងបរិបទច្បាប់កម្ពុជា

**ប្រធានសក្តិ នៅក្នុងបរិបទច្បាប់កម្ពុជា** .......... 35
១. សេចក្តីផ្តើម .......... 35
២. តួសេចក្តី .......... 35
៣. ចុងបញ្ចប់នៃអត្ថបទ ឬ សេចក្តីសន្និដ្ឋាន .......... 38

# សកម្មភាពរបស់គណៈមេធាវី

១.ទំនាក់ទំនងជាតិ និងអន្តរជាតិ .......... 41
១.១ ទំនាក់ទំនងជាតិ .......... 41
១.២ ទំនាក់ទំនងអន្តរជាតិ .......... 49
២. ការផ្សព្វផ្សាយច្បាប់តាមរយៈសិក្ខាសាលា .......... 57

# សាររបស់ប្រធានគណៈមេធាវី



គណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជាមានកិត្តិយស សូមបោះពុម្ពបន្តនូវ ព្រឹត្តិបត្រមេធាវីលេខ ២៣ សម្រាប់ត្រីមាសទី១ខែមករា-មីនា ឆ្នាំ២០២០។ ព្រឹត្តិបត្រមេធាវីនេះបានសម្រេចឡើងដោយ ការប្រឹងប្រែង លះបង់ពេលវេលាដ៏មានតម្លៃរបស់អ្នកនិពន្ធ ម្នាក់ៗ ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍របស់គាត់ ។ តាងនាមឱ្យគណៈមេធាវី ខ្ញុំសូមថ្លែងអំណរគុណដល់អ្នកនិពន្ធ ដែលបានរួមចំណែកវិភាគទានអត្ថបទរបស់ខ្លួន ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់លោកអគ្គលេខាធិការ លោកអគ្គលេខាធិការរង ប្រធានបុគ្គលិក និងអ្នកស្ម័គ្រចិត្តនៃនាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយនៃគណៈមេធាវីដែលបានខិតខំរៀបចំពិនិត្យ និងសម្រួលអត្ថបទ និងការបោះពុម្ពព្រឹត្តិបត្រលេខនេះ។

ព្រឹត្តិបត្រលេខនេះប្រមូលផ្តុំនូវអត្ថបទនៅក្នុងវិស័យនានា ដូចជា ព្រហ្មទណ្ឌ ច្បាប់ បរធនបាលកិច្ចនៅកម្ពុជា និងករណីប្រធានសក្តិ នៅក្នុងបរិបទច្បាប់កម្ពុជា ជាដើម។ បន្ថែមលើការផ្សាយនូវអត្ថបទច្បាប់ ព្រឹត្តិបត្រមេធាវីបានផ្តល់ព័ត៌មានស្តីពី សកម្មភាពនៃគណៈមេធាវី ដើម្បីឲ្យសហភាតារជាមេធាវីបានជ្រាបពីកិច្ចដំណើរការនៃគណៈមេធាវី។ គណៈមេធាវីនឹងស្វះស្វែងទាក់ទងមេធាវី និងអ្នកច្បាប់ដទៃទៀត ដើម្បីពង្រីកការចែករំលែកនូវចំណេះដឹងនៅក្នុងវិស័យដទៃទៀត នៅក្នុងការផ្សាយលើកក្រោយៗ។

ការបោះពុម្ពផ្សាយព្រឹត្តិបត្រមេធាវីនេះជាការឆ្លើយតបទៅនឹង**ទិសដៅទី២ "ពង្រឹង និងការពារវិជ្ជាជីវៈ"** **នៃផែនការសកម្មភាពនៃគណៈមេធាវី** ដែលបានអនុម័តដោយក្រុមប្រឹក្សា-គណៈមេធាវី។

ខ្ញុំសង្កេតឃើញថា នៅក្នុងសហគមន៍អ្នកច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងមានអ្នកជំនាញខាងច្បាប់ជាច្រើន ដែលបានសរសេរផ្សព្វផ្សាយសៀវភៅសិក្សា ដើម្បីបម្រើ

សេចក្តីត្រូវការនៃអ្នកសិក្សាច្បាប់។ ទោះបីមិនមែនជាអ្នកជំនាញក៏ដោយ ខ្ញុំសូមលើកទឹកចិត្តដល់មេធាវី និងអ្នកសិក្សាទូទៅចូលរួមវិភាគទានអត្ថបទ ដើម្បីចុះផ្សាយក្នុងព្រឹត្តិបត្រមេធាវី។ គណៈមេធាវីស្វាគមន៍ជានិច្ចដល់ការចូលរួមចែករំលែកអត្ថបទរបស់ខ្លួននៅក្នុងព្រឹត្តិបត្រនេះ។ ចំពោះអ្នកដែលមានបំណិនខាងសរសេរមានកម្រិត គណៈមេធាវីមានក្រុមបណ្ណាធិការមួយដែលនឹងជួយផ្តល់ការណែនាំដល់អ្នកចូលរួម និងជួយកែសម្រួលអត្ថបទ។ គោលដៅនៃការបង្កើតព្រឹត្តិបត្រនេះ មិនត្រឹមតែផ្សព្វផ្សាយអត្ថបទនៃអ្នកនិពន្ធជើងចាស់តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយលើកស្ទួយបំណិនខាងសរសេរដល់អ្នកនិពន្ធជំនាន់ក្រោយផងដែរ។

ខ្ញុំយល់ឃើញថា ថ្វីបើក្រុមបណ្ណាធិការបានផ្ចិតផ្ចង់ក្នុងការធ្វើឲ្យព្រឹត្តិបត្រទទួលបានគុណភាពមួយដ៏ខ្ពស់ក៏ដោយ ការខ្វះខាតគង់តែជៀសមិនផុត។ ដើម្បីជ្រោមជ្រែងឲ្យព្រឹត្តិបត្រនេះមានគុណភាពកាន់តែប្រសើរ ខ្ញុំសូមអំពាវនាវដល់អ្នកអានមេត្តាសរសេរតប និងរិះគន់ស្ថាបនាធ្វើអត្ថាធិប្បាយ ឬបំពេញបន្ថែមទៅលើអត្ថបទនីមួយៗដែលបានបោះពុម្ពផ្សាយ។ ខ្ញុំសង្ឃឹមថា សហភាតា ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រីនឹងបានរីករាយក្នុងការអានព្រឹត្តិបត្រមេធាវីលេខនេះ។

ចំពោះការចូលរួមវិភាគអត្ថបទ សូមធ្វើការទាក់ទងមកការិយាល័យគណៈមេធាវីដោយផ្ទាល់តាមរយៈលោកមេធាវី **ភុយ នាម** តាមអ៊ីម៉ែល neam130@bakc.org.kh និងលោកមេធាវី **វ៉ា សំរិត** តាមអ៊ីម៉ែល samrit@bakc.org.kh ក៏បាន។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់សហភាតា ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រីទាំងអស់ សូមជួបតែជោគជ័យគ្រប់ប្រការ។

សូមអរគុណ!

ថ្ងៃអង្គារ ៨កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០



**សួន វិសាល**

ប្រធានគណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជា

# ព្រហ្មទណ្ឌ

# បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

## Crime against Humanity

ដោយបណ្ឌិត មាស បូរ៉ា និង លោក សាន វិច្ឆរ៉ា*

## ១. សេចក្តីផ្តើម

បទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិ (crimes under international law) ជាចំបងមានបទប្រល័យពូជសាសន៍ (genocide) បទឧក្រិដ្ឋកម្មសង្គ្រាម និងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ឯកសារជាច្រើន បានចែងអំពីបទ បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នេះដូចជា លក្ខន្តិកៈទីក្រុងរ៉ូម ច្បាប់ស្តីពី ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក) ក្រមព្រហ្មទណ្ឌកម្ពុជា (សូមមើលឧបសម្ព័ន្ធ)។ អត្ថបទខ្លីនេះ គ្មានគោលបំណងបរិយាយលម្អិតទាំងស្រុងឡើយ គ្រាន់តែព្យាយាម បង្ហាញនូវខ្លឹមសារគោលនៃបទ បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងបញ្ហាពាក់ព័ន្ធមួយចំនួន សម្រាប់ជាមូលដ្ឋានដល់អ្នកសិក្សា សិក្សាបន្តទៀត។ អត្ថបទ នឹងចាប់ផ្តើមអំពីភាពខុសគ្នា ជាសង្ខេបរវាងបទឧក្រិដ្ឋទាំងបី និងបន្តដោយខ្លឹមសារចម្បងនៃ បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយពិចារណានូវបទប្បញ្ញត្តិចែងពី បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងក្រម ព្រហ្មទណ្ឌកម្ពុជា និងយោងដល់យុត្តិសាស្ត្រ ឬបទប្បញ្ញត្តិនៃអត្ថបទគតិយុត្តផ្សេងទៀតដើម្បីបំភ្លឺបន្ថែម។

## ២.ខ្លឹមសារ

### ២.១. ភាពខុសគ្នារវាង បទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មសង្គ្រាម និង បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

ជាបឋម គេគួរកត់សំគាល់ថាពាក្យ «បទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិ» និង «បទឧក្រិដ្ឋអន្តរជាតិ» (international crimes) មានខ្លឹមសារខុសគ្នា។ បទល្មើសខាងក្រោយនេះមានច្រើនសំខាន់ឲ្យតែមានលក្ខណៈឆ្លងប្រទេស (transnational)។[1]

---

*លោក មាស បូរ៉ា ជាមេធាវី និងជាអ្នកស្រាវជ្រាវច្បាប់។ លោក សាន វិច្ឆរ៉ា ជានិស្សិតអនុបណ្ឌិត និងអ្នកស្រាវជ្រាវច្បាប់ នៃសាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា។

[1] អំពើភេរវកម្មជាបទឧក្រិដ្ឋអន្តរជាតិ។

ភាពខុសគ្នាជាចម្បងនៃបទល្មើសទាំងបីខាងលើ គឺពេលវេលាក្នុងអំឡុង ដែលបទឧក្រិដ្ឋត្រូវបានប្រព្រឹត្ត និងជនរងគ្រោះ។ បទឧក្រិដ្ឋកម្មសង្គ្រាម ត្រូវបានប្រព្រឹត្តិនៅក្នុងអំឡុងពេលសង្គ្រាមអន្តរជាតិ (International Armed Conflict)[2] ក៏ប៉ុន្តែបទប្រល័យពូជសាសន៍ និង បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អាចត្រូវបានប្រព្រឹត្តក្នុងពេលសន្តិភាព។ ជនរងគ្រោះនៃបទប្រល័យពូជសាសន៍ គឺក្រុមពូជសាសន៍ រីឯ បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជនរងគ្រោះអាចជានរណាក៏បាន សូម្បីប្រជាពលរដ្ឋស៊ីវិល នៃអំពើល្មើសរបស់មេដឹកនាំរបស់ខ្លួន។ ចំណែកឯជនរងគ្រោះនៃបទ បទឧក្រិដ្ឋកម្មសង្គ្រាម គឺជាទាហាន ឬកងកម្លាំងប្រដាប់អាវុធ ឬជនស៊ីវិលដែលចូលរួមផ្ទាល់ក្នុងជម្លោះប្រដាបអាវុធ ដូចជា កាន់កាំភ្លើងបាញ់ជាដើម។[3]

សម្រាប់អំពើប្រល័យពូជសាសន៍ វាទាមទារឲ្យមានចេតនាជាក់លាក់ (specific intent) នោះគឺការសម្លាប់ដើម្បីបំបាត់ពូជសាសន៍។ បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋកម្មសង្គ្រាម មិនទាមទារដូចនេះទេ។ ជាចុងក្រោយ មុននឹងចាកចេញពីបញ្ហានេះ គេគួរកត់សំគាល់ថា បទឧក្រិដ្ឋកម្មសង្គ្រាម ត្រូវបានចែងហាមជាយូរមកហើយ ដែលនាំឲ្យមានការអះអាងថា វាជាបទឧក្រិដ្ឋក្រោមវិធានទំនៀមទម្លាប់អន្តរជាតិ។ បទនេះ មានមុន បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងន័យថា បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទើបក្លាយជាបទឧក្រិដ្ឋដោយឡែកនាពេលក្រោយមក។ ពីមុន បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ស្ថិតនៅក្នុង ឆ័ត្រនៃ បទឧក្រិដ្ឋកម្មសង្គ្រាម។ ក្នុងក្តីក្តាំនៅមុខ អវតក ជនត្រូវចោទ អះអាងថា បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមឆ័ត្រ របស់ បទឧក្រិដ្ឋកម្មសង្គ្រាម។ ប្រសិនបើចង់ចោទពីបទ បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ព្រះរាជអាជ្ញាត្រូវបង្ហាញ ថាមានជម្លោះប្រដាប់អាវុធផងដែរ។[4] ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះបានអះអាងថា បទឧក្រិដ្ឋកម្មសង្គ្រាម និង បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដាច់ដោយឡែកពីគ្នា តាំងពីមុនឆ្នាំ ១៩៧៥ (ច្បាប់អាចអនុវត្តនៅ

---

[2]សង្គ្រាមរវាងប្រទេស និងប្រទេស។ ទោះបីជាយ៉ាងនេះក្តី វាអាចត្រូវបានប្រព្រឹត្តនៅក្នុងសង្គ្រាមស៊ីវិលក្នុងស្រុក ដែលអាចស្ថិតក្នុងយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC), សូមមើល Antonio Casses, International Criminal Law, Cases & Commentary, 2011, p. 117។

[3]Israel Supreme Court, Public Committee against Torture in Israel v Israel and ors, HCJ 769/02, 13 December 2006, Holding 7 and 8.

[4] IENG Sary's Alternative Motion on the Limits of the Applicability of Crimes against Humanity at the ECCC, D287/2, 23 June 2010, para.8.

មុខ អវតក) ដើម្បីកុំឲ្យមានការចោទប្រកាន់ត្រួតគ្នា (cumulative charges) ដែលខុសនឹងវិធានច្បាប់។[5]

## ២.២. បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងក្រមព្រហ្មទណ្ឌកម្ពុជា

ក្រោយពេលកម្ពុជាចូលជាភាគីនៃលក្ខន្តិកៈទីក្រុងរ៉ូម បង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)[6] និងស្របពេលដែលកម្ពុជាកំពុងរៀបចំសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី បទប្បញ្ញត្តិស្តីពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានស្នើឲ្យដាក់បញ្ចូល ហើយជាចុងក្រោយ ឃើញមានវត្តមានក្នុងមាត្រា ១៨៨។ មាត្រា ១៨៨ មានខ្លឹមសារ ស្រដៀងគ្នានឹងមាត្រា ៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម។ បន្ថែមពីលើនេះ មានមាត្រាមួយចំនួនទៀតដែលពាក់ព័ន្ធ ចែងអំពីទោស ដែលមានទោសខ្ពស់បំផុត គឺដាក់ពន្ធនាគារមួយជីវិត[7] ការចោទប្រកាន់បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គ្មានផុតអាជ្ញាយុកាលទេ។[8] ក្រៅពីការដាក់ទោសទណ្ឌដល់រូបវន្តបុគ្គល ក៏មានការដាក់ឲ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌដែរ ជាមួយនឹងពិន័យរហូតដល់៥០០លានរៀល។[9]

### ២.២.១. ខ្លឹមសារ

មាត្រា ១៨៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រាដទៃទៀតស្តីពី បទឧក្រិដ្ឋកម្មសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ចែងស្រដៀងគ្នា ជាពីរផ្នែក គឺធាតុផ្សំរួម (chapeau element) និងបទល្មើសតូចៗ ដូចជា មនុស្សឃាត ឬទារុណកម្មជាដើម។ ធាតុផ្សំរួមរបស់បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មានការវាយប្រហារជាទូទៅ (general attack) ឬជាប្រព័ន្ធ (systematic attack) ទៅលើជនស៊ីវិល។ ពាក្យថា "ការវាយប្រហារ" សំដៅលើសកម្មភាពជាច្រើន កើតក្នុងទីតាំងណាមួយ ឬច្រើនក្នុងប្រទេស ដែលនេះជាការវាយប្រហារទូទៅ។ រីឯការវាយប្រហារជាប្រព័ន្ធបង្កប់នូវខ្សែសង្វាក់បញ្ជា តាមគោលនយោបាយ។ ក្នុងន័យនេះ ការវាយ

[5] Pre-Trial Chamber, Decision on MEAS Muth's Appeal against the International Co-Investigating Judge's Decision on MEAS Muth's Request for Clarification Concerning Crimes against Humanity and the Nexus with Armed Conflict, 10 April 2017, D87/2/1.7/1/1/7, para. 65 (confidential).

[6] UN General Assembly, Rome Statute of the International Criminal Court (last amended 2010), 17 July 1998, ISBN No. 92-9227-227-6, available at: https://www.refworld.org/docid/3ae6b3a84.html [accessed 12 April 2020]។ កម្ពុជាចុះហត្ថលេខា ក្នុងថ្ងៃទី ២៣ ខែវិច្ឆិកា ២០០០ និងក្លាយជាភាគី ១១ មេសា ២០០២។

[7] មាត្រា ១៨៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។ កម្ពុជាបានលុបទោសប្រហារជីវិត (មាត្រា ៣២ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣)។

[8] មាត្រា ១៩៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។

[9] មាត្រា ១៩២ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។

ប្រហារទាំងពីរ បង្ហាញពីការចូលរួមដោយមនុស្សច្រើន ហើយជនរងគ្រោះ ក៏អាចនឹងមានច្រើនផងដែរ។ អាស្រ័យហេតុនេះ ទើបគេចាត់ថាវាជាបទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិ ដែលការប្រព្រឹត្តប៉ះពាល់ធ្ងន់ធ្ងរដល់សង្គម និងសន្តិភាព និងត្រូវបានដាក់ឲ្យស្ថិតក្នុងសមត្ថកិច្ចរបស់តុលាការ ដាក់បុគ្គលឲ្យទទួលខុសត្រូវ កុំឲ្យរួចខ្លួនពីសំណាញ់ច្បាប់។

ជាចុងក្រោយ មាត្រា ១៨៨ មិនបានចែងដូច មាត្រា ៥ របស់ អវតក ដែលមានឃ្លា "ដោយមាន ការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ណាមួយ" ទេ។ ដូចនេះ បញ្ហាផ្លូវច្បាប់កើតមាននៅ អវតក មិនមានចោទទេនៅចំពោះ មុខតុលាការកម្ពុជា នាពេលខាងមុខ ក្នុងករណីមានការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនេះ។ យុត្តិសាស្ត្រ អវតក បំភ្លឺថា ធាតុផ្សំរើសអើង នេះមិនអនុវត្តចំពោះធាតុផ្សំរួម និង បទល្មើសដទៃ ដែលគ្មានចរិតរើសអើងទេ។ វាអនុវត្តន៍សម្រាប់តែ បទល្មើសធ្វើទុក្ខបុកម្នេញ (persecution) តែប៉ុណ្ណោះ។

មានសំណួរច្បាប់ចោទឡើងនៅមុខ អវតក ថាទាហានដែលត្រូវបានចោទថាក្បត់ ត្រូវបានសម្លាប់ ដោយមេដឹកនាំរបស់ខ្លួន នឹងត្រូវចាត់ថា ជនស៊ីវិល (បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ) ឬទាហាន ក្រោមឆ័ត្រនៃ បទឧក្រិដ្ឋកម្មសង្គ្រាម។ អ្នកជំនាញអះអាង ត្រូវចាត់ថាពួកគេជាជនស៊ីវិល។[10]

មាត្រា ១៨៨ ចែងនូវប្រភេទល្មើស ចំនួន ១១ ដែលអាចចាត់ជាបទល្មើសផ្សេងៗ ដូចជា ទារុណកម្ម មនុស្សឃាតជាដើម។ ទោះបីជាយ៉ាងនេះក្តី ឃ្លាចុងក្រោយ "១១- គ្រប់អំពើអមនុស្សធម៌ផ្សេងទៀត ដែលបង្កឱ្យមានការឈឺចាប់យ៉ាងខ្លាំង ឬការប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើបូរណភាពខាងរូបកាយ" អាចរាប់នូវអំពើផ្សេងៗទៀត ដែលស្ថិតក្នុងកម្រិតចាត់ជាបទល្មើសដែលអាចចូលក្នុងយុត្តាធិការរបស់តុលាការ។

## ២.២.២. ធាតុផ្សំ ដែលព្រះរាជអាជ្ញាត្រូវបង្ហាញ

ធាតុផ្សំនៃបទល្មើស បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលព្រះរាជអាជ្ញាត្រូវបង្ហាញខុសគ្នានឹងបទល្មើសក្រោមច្បាប់ជាតិ។ ព្រះរាជអាជ្ញាត្រូវបង្ហាញធាតុផ្សំសម្ភារៈ (សកម្មភាព) និងអត្តនោម័តក្នុងពីរកម្រិត។ ជាដំបូងត្រូវបង្ហាញ តាមរយៈភស្តុតាងផ្ទាល់ ឬមិនប្រយោល (circumstantial evidence) ថាមានការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធលើជនស៊ីវិល។

[10] Queen's University Belfast Human Rights Centre response to the ECCC Office of the Co-Investigating Judges' Call for Submissions by the Parties in Cases 003 and 004 and Call for Amicus Curiae Briefs, 12 May 2016, para. 18.

ព្រះរាជអាជ្ញា ក៏ត្រូវបង្ហាញពីបទល្មើសតូចនីមួយៗ[11] ដែលខ្លួនបានចោទលើជនសង្ស័យ ដូចជា អំពើទារុណកម្ម ដែលប្រព្រឹត្តិឡើងក្នុងក្របខ័ណ្ឌនៃការវាយប្រហារ។ ដោយសារក្រមព្រហ្មទណ្ឌកម្ពុជា ឬឯកសារពាក់ព័ន្ធ មិនបានចែងលម្អិត អំពីធាតុផ្សំនៃបទល្មើសតូចៗ ក្នុងមាត្រា ១៨៨ ការពិចារណានូវវិធាន ឬយុត្តិសាស្ត្រអន្តរជាតិ គួរត្រូវបានយោង។

សម្រាប់អំពើទារុណកម្ម ព្រះរាជអាជ្ញាត្រូវបង្ហាញថា មានអំពើបង្កឈឺចាប់ធ្ងន់ធ្ងរលើមនុស្សក្រោមការគ្រប់គ្រងរបស់ជនត្រូវចោទ។ ការឈឺចាប់ មិនមែនជាការឈឺចាប់ មកពីអំពើទណ្ឌកម្មស្របច្បាប់ (ដូចជាការឃុំខ្លួនស្របច្បាប់ទេ)។ ទង្វើប្រព្រឹត្តជាផ្នែកមួយ នៃការវាយប្រហារទូទៅ ហើយជនល្មើសដឹងថា ទង្វើនោះគឺជាផ្នែកនៃការវាយប្រហារនោះ។ ក្នុងន័យនេះ ការធ្វើទារុណកម្ម ដើម្បីជម្រិតយកលុយ មកទិញអាហារ ទំនងជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ក្នុងមាត្រា ១៨៨ នេះទេ។[12] តាមន័យនេះ ធាតុផ្សំអត្តនោម័ត គឺ ការដឹង។

## ៣. សង្ខេប

ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ មាត្រា ១៨៨ បានចែងអំពី បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងន័យលម្អិតច្រើន។ មាត្រា បានចែងអំពីធាតុផ្សំសម្ភារៈ និង អត្តនោម័ត។ មកដល់ពេលនេះ មិនទាន់មានសាលក្រមនៃតុលាការ កម្ពុជាណាមួយពាក់ព័ន្ធនឹង បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ យុត្តិសាស្ត្រ អវតក និង តុលាការព្រហ្មទណ្ឌជាតិ ឬអន្តរជាតិ ជាច្រើន បានបំភ្លឺនូវខ្លឹមសារនៃ បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ខុសពីការបង្ហាញធាតុផ្សំ

[11] ក្នុងដីកាចោទ បទល្មើសនីមួយៗ គេហៅថា count ។

[12] មាត្រា ៧ (១) (ច) ទារុណកម្មធាតុផ្សំ៖ ១. ចារីបានធ្វើបាបមនុស្សម្នាក់ឬច្រើននាក់ដែលនាំឲ្យឈឺចាប់ ឬ រងទុក្ខធ្ងន់ធ្ងរមិនថារាងកាយ ឬផ្លូវចិត្ត ។ ២. បុគ្គលស្ថិតនៅក្រោមការគ្រប់គ្រង ឬការត្រួតពិនិត្យរបស់ចារី ។ ៣. ការឈឺចាប់ ឬការរងទុក្ខ មិនកើតមកពីទណ្ឌកម្មស្របច្បាប់និងមិនបង្កដោយការដាក់ទណ្ឌកម្មស្របច្បាប់ ។ ៤. ទង្វើប្រព្រឹត្តគឺជាផ្នែកមួយនៃការវាយប្រហារទូទៅ ឬជាប្រព័ន្ធទៅលើប្រជាជនស៊ីវិល ។ ៥. ចារីបានដឹងថាទង្វើ នេះគឺជាផ្នែកមួយនៃការវាយប្រហារទូទៅ ឬជាប្រព័ន្ធទៅលើប្រជាជនស៊ីវិល (1.The perpetrator inflicted severe physical or mental pain or suffering upon one or more persons; 2. Such person or persons were in the custody or under the control of the perpetrator; 3.Such pain or suffering did not arise only from, and was not inherent in or incidental to, lawful sanctions; 4. The conduct was committed as part of a widespread or systematic attack directed against a civilian population, and 5. The perpetrator knew that the conduct was part of or intended the conduct to be part of a widespread or systematic attack directed against a civilian population), សូមមើល Elements of Crimes, 2011, ISBN No. 92-9227-232-2, available at: https://www.refworld.org/docid/4ff5dd7d2 .html [accessed 11 April 2020]

នៃបទល្មើសក្រោមច្បាប់ជាតិ ការបង្ហាញធាតុផ្សំ នៃ បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មានវិសាលភាព និងភាពស្មុគស្មាញ ដោយបង្ហាញទាំងធាតុផ្សំរួម និងបទល្មើស តូចៗដោយឡែកទៀត។ ធាតុផ្សំអត្តនោម័ត គឺការដឹង។

## ៤. តារាងប្រៀបធៀបបទប្បញ្ញត្តិ

| ល | ច្បាប់ | ខ្លឹមសារ |
|---|---|---|
| ១ | លក្ខន្តិកៈ ទីក្រុងរ៉ូម | មាត្រា ៧ ៖ អំពីបទល្មើសព្រហ្មទណ្ឌប្រឆាំងមនុស្សជាតិ ១.សម្រាប់គោលបំណងនៃលក្ខន្តិកៈនេះ ពាក្យបទល្មើស ប្រឆាំងមនុស្សជាតិ មានន័យថាជាអំពើណាមួយដូចតទៅនេះ ដែលត្រូវបានប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហារទូទៅ ឬជាប្រព័ន្ធប្រឆាំងនឹងប្រជាពលរដ្ឋស៊ីវិល ដោយមានការដឹងពីការវាយប្រហារនោះ ៖ (ក)ឃាតកម្ម។ (ខ) ការសម្លាប់រង្គាល។ (គ)ការដាក់មនុស្សឲ្យធ្វើជាទាសករ។ (ឃ)ការនិទេស ឬការផ្លាស់ទីប្រជាពលរដ្ឋដោយបង្ខិតបង្ខំ។(ង)ការដាក់ពន្ធធនាគារ ឬ ការដកហូតសេរីភាពខាងរូបកាយ ដែលជាការបំពានលើវិធានជាមូលដ្ឋាននៃច្បាប់អន្តរជាតិ។ (ច)ការធ្វើទារុណកម្ម។ (ឆ)រំលោភសេពសន្ថវៈទាសកម្មផ្លូវភេទ ពេស្យាចារដោយបង្ខំ ការមានគភ៌ដោយបង្ខំ វញ្ញកម្មដោយដាក់បង្ខំ ឬការបំពានផ្លូវភេទក្នុងទ្រង់ទ្រាយផ្សេងទៀតដែលមានភាពធ្ងន់ធ្ងរប្រហែលគ្នានេះ។ (ជ) ការធ្វើទុក្ខបុកម្នេញលើក្រុមជាក់លាក់ណាមួយ ឬ ជារួម ដោយមូលហេតុនយោបាយ ពូជសាសន៍ ជាតិសាសន៍ ជាតិពន្ធុ វប្បធម៌ សាសនា យេនឌ័រដូចបានកំណត់និយមន័យក្នុងកថាខ័ណ្ឌទី៣ ឬ មូលដ្ឋានផ្សេងទៀត ដែលត្រូវបានទទួលស្គាល់ជាសកល មិនអនុញ្ញាតឲ្យធ្វើក្រោមច្បាប់អន្តរជាតិ ទាក់ទងនឹងអំពើណាមួយដែលបានចែងក្នុងកថាខ័ណ្ឌនេះ ឬបទល្មើសព្រហ្មទណ្ឌណាមួយ ដែលស្ថិតក្នុងយុត្តាធិការតុលាការ។ (ឈ)ការបាត់ខ្លួនមនុស្សដោយដាក់បង្ខំ។ (ញ)បទល្មើសព្រហ្មទណ្ឌអាប៉ាថេដ។ (ដ)អំពើអមនុស្សធម៌ដែលមានលក្ខណៈជាអន្តរជាតិស្រដៀងគ្នាដទៃទៀត ដែលបង្កនូវការ |

| | | |
|---|---|---|
| | | ឈឺចាប់ធ្ងន់ធ្ងរ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរដល់រូបកាយ ឬដល់សុខភាពខាងបញ្ញាស្មារតី និងរូបកាយ ។ |
| ២ | ច្បាប់ អវតក | មាត្រា៥ ៖ អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយ ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងអំឡុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ៦ ខែមករា ឆ្នាំ១៩៧៩។<br>ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលគ្មានអាជ្ញាយុកាល គឺអំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅឬ ដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុនយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនាណាមួយដូចជា៖ ១.ការធ្វើមនុស្សឃាត។ ២. ការសម្លាប់រង្គាល។ ៣. ការធ្វើឱ្យទៅជាទាសករ។ ៤.ការនិរទេស។ ៥.ការដាក់ក្នុងមន្ទីរឃុំឃាំង។ ៦.ការធ្វើទារុណកម្ម។ ៧.ការរំលោភលើផ្លូវភេទ។ ៨.ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា។ ៩.អំពើអមនុស្សធម៌ ផ្សេងៗទៀត។ |
| ៣ | ក្រមព្រហ្មទណ្ឌកម្ពុជា | មាត្រា ១៨៨ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ<br>បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ គឺជាអំពើណាមួយក្នុងចំណោមអំពើដែលរៀបរាប់ខាងក្រោមនេះកាលបើអំពើនេះត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃការវាយលុកជាទូទៅឬជាប្រព័ន្ធ សំដៅប្រឆាំងប្រជាជនស៊ីវិល ៖ ១- ឃាតកម្ម ។ ២- ការសម្លាប់រង្គាល ។ ៣- ការធ្វើឱ្យទៅជាទាសករ ។ ៤- ការនិរទេស ឬជម្លៀសប្រជាជនដោយបង្ខំ ។ ៥-ការដាក់ពន្ធនាគារឬគ្រប់រូបភាពដទៃទៀតនៃការដកហូតយ៉ាងធ្ងន់ធ្ងរនូវសេរីភាពដោយបំពានទៅលើបទប្បញ្ញត្តិគ្រឹះនៃនីតិអន្តរជាតិ ។ ៦- ការធ្វើទារុណកម្ម ។៧- ការចាប់បង្ខំសេពសន្ថវៈ ការធ្វើទាសករខាងផ្លូវភេទ ពេស្យាចារដោយបង្ខំ ការមានគភ៌ដោយបង្ខំ វណ្ឌកម្មដោយបង្ខំ និង គ្រប់រូបភាពផ្សេងទៀតនៃអំពើខាងផ្លូវភេទ ដែលមានទម្ងន់ប្រហាក់ប្រហែល |

| | | |
|---|---|---|
| | | គ្នា ។ ៨-ការធ្វើទុក្ខបុកម្នេញលើក្រុម ឬសមូហភាពដោយមូលហេតុនយោបាយ ពូជសាសន៍ ក្រុមជាតិ ជាតិពន្ធុ វប្បធម៌ សាសនា ឬភេទ ។ ៩- ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ។ ១០- ការអនុវត្តនយោបាយប្រកាន់ពូជសាសន៍ជាប្រព័ន្ធតាមបែបអាប៉ា-ថេដ ។១១- គ្រប់អំពើអមនុស្សធម៌ផ្សេងទៀត ដែលបង្កឱ្យមានការឈឺចាប់យ៉ាងខ្លាំង ឬការប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើបូរណភាពខាងរូបកាយ ។ |

# ការបញ្ឈប់ ឃាត់ខ្លួន និងឆែកឆេរ

ដោយបណ្ឌិត មាស ប៉ូវ៉ា និង លោក នូ គីមឈីវ*

## ១.សេចក្តីផ្តើម

ដំណើរការរឿងក្តីព្រហ្មទណ្ឌ ចាប់ផ្តើមពី ការបញ្ឈប់ (stop) ឃាត់ខ្លួន សួរនាំ ឈានទៅដល់ ការឃុំខ្លួន និងចុងបញ្ចប់សវនការរកខុសឬត្រូវ។ ជាទូទៅ វាចាប់ផ្តើមជាមួយនឹង កិច្ចរបស់ប៉ូលីស ដូចជាការឃាត់ខ្លួនជនសង្ស័យណាមួយ ដែលនាំឲ្យដំណើរការនីតិវិធីបានចាប់ផ្តើម។

ការឃាត់ខ្លួន ឬស្រាវជ្រាវ សុទ្ធតែអាចប៉ះពាល់នូវសេរីភាពបុគ្គល ជីវិតឯកជន ឬទ្រព្យសម្បត្តិ។ អាស្រ័យហេតុនេះ វាតម្រូវឲ្យមានវិធាន ឬស្តង់ដាសម្រាប់ជាមូលដ្ឋានក្នុងការឃាត់ខ្លួន។ អត្ថបទខ្លីនេះ នឹងបង្ហាញ ជាចម្បងអំពី កម្រិត និងប្រភេទនៃភស្តុតាង ដែលទាមទារឲ្យគោរពតាម ដែលប្រសិនបើមិនដូចនេះទេ អាចនាំឲ្យមានញត្តិ (motion) សុំមោឃៈភាព ឬភស្តុតាងទទួល បានពីការឃាត់ ឬស្រាវជ្រាវ គ្មានតម្លៃជាភស្តុតាងទេ។ ជាដំបូង អត្ថបទនឹងបង្ហាញអំពីកិច្ចមួយចំនួន និង កម្រិតនៃភស្តុតាង (standard of proof) ដែលតម្រូវ និងមានភាពខុសគ្នាក្នុងចំណោមកម្រិតភស្តុតាងទាំងនោះ។ ផ្នែកចុងក្រោយ ជាសេចក្តីសង្ខេប។

## ២. ខ្លឹមសារ

### ២.១. ភាពខុសគ្នានៃកម្រិតភស្តុតាង

កិច្ច ឬកម្រិតភស្តុតាង វាខុសគ្នា ទៅតាមប្រព័ន្ធច្បាប់ដែល ដំណើរការក្តីព្រហ្មទណ្ឌស្ថិតនៅក្នុងនោះ។ ក្នុងប្រព័ន្ធច្បាប់ទាំងពីរ (កំមុនឡូ និង ស៊ីវិលឡូ) ដំណើរការរឿងព្រហ្មទណ្ឌជាទូទៅ ចាប់ផ្តើមពី ប៉ូលីស ទោះបីជាកិច្ច ឬលទ្ធផលនៃកិច្ចមានកម្រិត ឬផលវិបាកខុសគ្នាក្តី។ កម្រិតភស្តុតាងក៏ខុសគ្នាដែរ។ ព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ផ្អែកលើមូលដ្ឋានមានហេតុផល ជឿថា (reason to believe) បទល្មើសត្រូវបានប្រព្រឹត្តិ។[13] ចៅក្រម

---

*បណ្ឌិត មាស ប៉ូវ៉ា ជាមេធាវី និងអ្នកស្រាវជ្រាវច្បាប់។ លោក នូ គីមឈីវ ជានិស្សិតអនុបណ្ឌិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងជាអ្នកស្រាវជាវច្បាប់ របស់សាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា។

[13] Internal Rules of the ECCC, Rule 53, available at https://www.eccc.gov.kh/sites/default/files/legal-documents/Internal_Rules_Rev_9_Eng.pdf

ស៊ើបអង្កេត អាចឃុំបាន ក្នុងករណីចាំបាច់[14]ហើយដាក់ក្រោមការស៊ើបអង្កេត លុះត្រាមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថា ជនត្រូវចោទបានចូលរួមប្រព្រឹត្តបទល្មើស។[15]ក្រោយពីស៊ើបអង្កេតចប់ ចៅក្រមសម្រេចបញ្ជូនទៅជំនុំជម្រះផ្អែកលើកម្រិតភស្តុតាង"ភស្តុតាងគ្រប់គ្រាន់.."[16] ឬលើកលែងចោទ ប្រសិនបើគ្មានភស្តុតាងគ្រប់គ្រាន់ (sufficient evidence)។ ព្រះរាជអាជ្ញា ត្រូវបង្ហាញហួសពីវិមតិសង្ស័យ ថាជនត្រូវចោទបានប្រព្រឹត្ដ ដើម្បីឲ្យតុលាការសម្រេចថា មានទោស (guilt)។[17] ចៅក្រមសម្រេចដោយឥស្សរចិត្ត (intimate) ដែលមានន័យថា ភស្តុតាង ធ្វើឲ្យជឿថា បទល្មើសត្រូវបានប្រព្រឹត្តិដោយជនត្រូវចោទ។[18] ជនត្រូវចោទ លើកអំណះអំណាងការពារខ្លួន ឧទាហរណ៍ ថាខ្លួនមិនបានប្រព្រឹត្តទេ ពីព្រោះក្នុងពេលកើតហេតុ ខ្លួនមិនបាននៅទីកើតហេតុទេ (alibi) ដោយប្រើ balance of probability (៥០%១)។[19]

កម្រិតភស្តុតាងសម្រាប់ការបញ្ឈប់ ឃាត់ ឬស្រាវជ្រាវ ដោយប៉ូលីស មិនមានចែងកំណត់ទេ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ អាស្រ័យហេតុនេះ ការយោងដល់យុត្តិសាស្ត្រ ឬការអនុវត្តរបស់បរទេស ដើម្បីបំភ្លឺ ពិតជាការចាំបាច់។

## ២.២. ការសង្ស័យមានហេតុផល និង Probable Cause (PC)

កម្រិតភស្តុតាងសម្រាប់ បញ្ឈប់បុគ្គលណាមួយ និង ឆែកលើរាងកាយ ឬទ្រព្យសម្បត្តិខុសគ្នា។ សម្រាប់ទី១ គឺ ការសង្ស័យដោយមានហេតុផល (reasonable suspicion: RS) រីឯសម្រាប់កិច្ចទី២ គឺ probable cause ។ ទាំងពីរនេះ មានកម្រិតខុសគ្នា មានខ្លឹមសារអរូបិយ នឹងត្រូវបានសម្រេច ថាបានបំពេញកម្រិតនៃភស្តុតាងនីមួយៗ ទៅតាមករណីជាក់ស្តែងនីមួយៗ។

---

[14] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧ មាត្រា ២០៥។ ក៏ប៉ុន្តែ វិធានផ្ទៃក្នុងនៃ អវតក វិធាន ៦៣ ទាមទារពីរលក្ខខណ្ឌ៖ ទី ១. មានហេតុផលរឹងមាំជឿបានថា បុគ្គលអាចប្រព្រឹត្ត និងការឃុំជាការចាំបាច់។

[15] ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ មាត្រា ១២៦។

[16] ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ មាត្រា ២៤៧។ សូមមើល មាស ប៊ូរ៉ា កម្រិត និងបន្ទុកភស្តុតាង, at www.measboralaws.com។

[17] ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ មាត្រា ២៤៧។

[18] ECCC Internal Rule 87, supra note 1. ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ មាត្រា ៣២១ (ដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន)។

[19] Ben Emmerson and Andrew Ashworth, Human Rights and Criminal Justice, 2 ed., 2007, p. 346; Goran Sluiter, Proof, in Antonio Cassese, the Oxford Companion to International Criminal Justice, 2009, p. 469។

មានអង្គហេតុជាច្រើនដូចជា ១. បុគ្គលធ្លាប់ប្រព្រឹត្តបទល្មើស ២. បុគ្គលចេញពីតំបន់បទល្មើសមានច្រើន ឬចូលទៅក្នុងតំបន់នោះ ៣. បុគ្គលឃើញប៉ូលីស រត់គេចដោយគ្មានហេតុផល (unprovoked flight) ៤. បុគ្គលធ្វើដំណើរដោយប្រើឈ្មោះក្លែង ឬពេលជួបនឹងប៉ូលីសដូចជាភ័យស្លន់ស្លោរ។ ទាំងអស់អាចត្រឹមតែជាអង្គហេតុនាំឲ្យសង្ស័យធម្មតា (not particularized suspicion)។ ការសង្ស័យដោយមានហេតុផល ទាមទារហួសពីនេះ។ ជាក់ស្តែង ពេលជួបនឹងប៉ូលីស បុគ្គលគេច មិនមែនដោយសារខ្លួនជាអ្នកប្រព្រឹត្តិល្មើស។ គាត់អាចជាមនុស្សល្អ (innocent) តែមិនចង់ពាក់ព័ន្ធ ខ្លាចមានគ្រោះថ្នាក់ដល់ខ្លួនជាដើម។ ដូចនេះ ក្រៅពីការគេចប៉ូលីស បុគ្គលមានកញ្ចប់គួរសង្ស័យជាមួយការប្រើឈ្មោះក្លែងក្លាយ ដែលទាំងអស់នេះ ធ្វើឲ្យការសង្ស័យរបស់ប៉ូលីស មានហេតុផល ឈានទៅបញ្ឈប់បុគ្គលនោះ ដោយគិតថាបុគ្គលអាចនឹងប្រព្រឹត្ត ឬចូលរួមប្រព្រឹត្តិបទល្មើស។

ការសង្ស័យដោយមានហេតុផល ជាកម្រិតភស្តុតាងទាបមួយ ដែលទាបជាង balance of probability (៥០%+១) ហើយ ការសង្ស័យដោយមានហេតុផល ទាបជាង PC។ សម្រាប់ការសង្ស័យដោយមានហេតុផល ប៉ូលីសសម្រេចដោយអត្តនោម័តខ្លួនឯង ដែលគាត់យល់ឬជឿដូចនេះ។ ការកំណត់ការសង្ស័យដោយមានហេតុផល ត្រូវផ្អែកតាមសុភវិនិច្ឆ័យ (commonsense) និងការទាញសន្និដ្ឋានពីទង្វើរបស់មនុស្ស។[20] ការសង្ស័យដោយមានហេតុផល ទាញចេញពី PC ហើយមិនតម្រូវទាមទារនូវការស៊ើបអង្កេតពេញលេញទេ វាគ្រាន់តែចាំបាច់ដើម្បីបញ្ឈប់បទល្មើសដែលនឹងបម្រុងកើតមាន។[21] ក៏ប៉ុន្តែ ដូចបានអះអាងខាងលើ ជាអប្បបរមា វាមិនអាចជាភស្តុតាងរាក់កំផែល ដើម្បីបញ្ឈប់បុគ្គលណាម្នាក់ដើម្បីសាកសួរទេ។ ក្រោយពីបញ្ឈប់ លើកលែង បទល្មើសជាក់ស្តែង ប៉ូលីសដែលត្រូវការឆែករាងកាយ ឬទ្រព្យសម្បត្តិជនសង្ស័យ ត្រូវមានដីកា ហើយផ្អែកតាម កម្រិតភស្តុតាង PC ដើម្បីឆែក។

PC សម្រាប់ការឆែក អាស្រ័យហេតុនេះ វាត្រូវខ្ពស់ជាងកម្រិតភស្តុតាង ការសង្ស័យដោយមានហេតុផល និង balance of probability ក៏ប៉ុន្តែទាបជាងកម្រិតភស្តុតាង beyond

[20] Determination of RS must be based on commonsense judgement and interferences about human behavior, p. 34។ ទោះបីជាយ៉ាងនេះក្តី តុលាការសិទ្ធិមនុស្ស អឺរ៉ុបបានកំណត់សញ្ញាណ RS ផ្សេងពីនេះ៖ …having a "reasonable suspicion "presupposes the existence of facts or information which would satisfy an objective observer that the person concerned may have committed the offence. What may be regarded as "reasonable" will however depend upon all the circumstances, Hartley v. UK, 12244/86, 30 August 1990, para. 32។

[21] Justice Marshall and Brennan Dissenting Opinion, United States v. Sokolow 490 U.S. 1(1989), in p.41 of Lore Rutz-Burri, Case Summaries on Criminal Procedure, 2015។

reasonable doubt។[22] ក្នុងន័យនេះ ភស្តុតាងតម្រូវក៏ទាមទារឲ្យមានច្រើន និងគួរឲ្យទុកចិត្តបានដែរ។ ភស្តុតាងអាចជាព័ត៌មានពីអ្នកផ្តល់ព័ត៌មាន (informant) ដែលជា hearsay evidence និងមានភាពចម្រូងចម្រាស់។ យុត្តិសាស្ត្រ អាមេរិក ប្រើវិធីសាស្ត្រចំនួនពីរ ដើម្បីកំណត់ PC សម្រាប់ប៉ូលីសុំដីកាពីចៅក្រម ដើម្បីស៊ើបអង្កេតបន្ត។ ទី១. ភាពទុកចិត្តបាននៃអ្នកផ្តល់ព័ត៌មាន និងមូលដ្ឋានព័ត៌មាន នៃអ្នកផ្តល់ និងទី ២. ពិចារណាលើគ្រប់ស្ថានភាព (totality of circumstances) ដែលចុងក្រោយនេះ ទំនងជាត្រូវបានទទួលយកជាទូទៅ។[23]

ដើម្បីបំពេញកម្រិតភស្តុតាង PC ភស្តុតាងត្រូវបង្ហាញនូវភាពជឿជាក់ថាបទល្មើសត្រូវបានប្រព្រឹត្ត ហើយអ្នកដែលត្រូវឃាត់ខ្លួន ជាបុគ្គលប្រព្រឹត្ត។[24] វាជា Objective Test ដែលយកការគិតរបស់មនុស្សមានហេតុផល (reasonable person) ផ្សេងពី ប៉ូលីសពាក់ព័ន្ធក្នុងសំណុំរឿង មកជាមូលដ្ឋាន។[25] វាពាក់ព័ន្ធនឹងភាពដែលអាចកើតមាន (probability)។ វាមិនមែនជាបច្ចេកទេសទេ គឺជាការពិចារណា តាមអង្គហេតុនិងការអនុវត្តជាក់ស្តែងក្នុងជីវិត។ ដូចនេះ អង្គហេតុ ឬព័ត៌មាន ទទួលបាន មិនគ្រាន់តែជា តម្រុយទេ (tip)ទេ។ វាត្រូវតែហួសពីនេះ និងច្រើនជាងនេះ។ ឧទាហរណ៍ មានការរាយការណ៍ថា នៅក្នុងបន្ទប់មួយ គេកំពុងប្រើអាភៀន ពេលប៉ូលីសទៅដល់ ធំក្លិនអាភៀនដែលគេកំពុងជក់ជាក់ស្តែង។ វាទំនងផ្អែកលើភាពតឹងរឹងនេះហើយ ទើបតុលាការ មានការប្រយ័ត្នក្នុងការ ចេញដីកាជាមុនជូនប៉ូលីស (anticipatory warrant)[26] តាមសំណើប៉ូលីស ឬ គាំទ្រវិធាន bright-line rule បង្កើតដោយប៉ូលីស ស្នើឲ្យឃុំជាបណ្តោះអាសន្ននូវបុគ្គលដែលឃើញប៉ូលីស គេចចេញ ដោយគ្មានមូលហេតុ (unprovoked flight/flee) [27] ឬក្នុងករណីជួញដូរគ្រឿងញៀន សុំឃាត់ខ្លួន អ្នកធ្លាប់នាំគ្រឿងញៀន (drug courier profile)។[28]

មូលហេតុ នៃការគេចពីប៉ូលីស មិនមែនថា គេជាជនសង្ស័យទេ តែបុគ្គលអាចមាន

[22] Lore Rutz-Burri, Case Summaries on Criminal Procedure, 2015, p.23។

[23] Illinois v. Gates 462 U.S. 213 (1983) in p. 49 of Lore Rutz-Burri, supra note 9។

[24] Lore Rutz-Burri, supra note 9, p.23។

[25] Lore Rutz-Burri, supra note 9, p.24។

[26] Lore Rutz-Burri, supra note 9, p.43។

[27] Dissenting Opinion of Justice Stevens, of Illinois v. Wardlow 528 U.S. 119 (2000) in p.34 of Lore Rutz-Burri, supra note 9។

[28] Reid v. Georgia 448 U.S. 438 (1980) in p. 39 of Lore Rutz-Burri, supra note 9។

មូលហេតុបន្ទាន់ផ្សេង ដូចជា ប្រញាប់ជួបមិត្តភ័ក្រ...។[29] ក្រៅពីជនមុខសញ្ញា គេត្រូវពិចារណាបន្ថែម អំពីថាតើគាត់មកពីកន្លែងជួយដូរគ្រឿងញៀនណាច្រើន ឬចូលទៅទីនោះ ហើយតើមានចង់ឃ្លូរសង្ស័យមានគ្រឿងញៀន ទើបអាចបំពេញ នូវ PC នាំទៅដល់ការឃាត់ឆែកលើរូបរាង និង កាបូប។[30]

## ២.៣. ទណ្ឌកម្មនៃការមិនគោរពវិធាន

បន្ទុកនៃការដាក់ភស្តុតាង ធ្លាក់ទៅលើប៉ូលីស ក្នុងការបំពេញកម្រិតភស្តុតាង ការសង្ស័យដោយមានហេតុផល ឬ PC។[31] ក្នុងករណី ការបញ្ឈប់ ឬ ឃាត់ខ្លួនដើម្បីឆែកឆេរ ដែលមិនបានបំពេញតាមកម្រិតភស្តុតាង ដែលទាមទារ វានឹងនាំឲ្យមានញត្តិ បដិសេធ ភស្តុតាងទទួលបានពីការឆែកនោះ (motion to suppress)។[32] បើវាជាការឃាត់ ឬឆែកខុសច្បាប់ ជនរងគ្រោះ អាចប្ដឹងទារសំណង ក្នុងទម្រង់ជាអំពើអនីត្យានុកូលភាព (tort) ហើយព័ត៌មាន ឬវត្ថុទទួលបាន នឹងគ្មានតម្លៃជាភស្តុតាងទេ។[33]

## ៣. សង្ខេប

ជាវិជ្ជាជីវៈ ឬវិធាន ព្រមទាំងយុត្តិសាស្ត្រតម្រូវ ការបញ្ឈប់ ឬឃាត់ខ្លួនមនុស្សម្នាក់ៗ ដើម្បីសាកសួរ ឬឆែកឆេរ ត្រូវគោរពតាមកម្រិតភស្តុតាង ដូចដែលបានរៀបរាប់ខាងលើ ដោយមិនចេះតែធ្វើឡើងងាយៗ គ្មានព័ត៌មាន ឬមូលដ្ឋានជាក់លាក់ តិចឬច្រើននោះទេ។ នេះដោយសារ វាអាចប៉ះពាល់ដល់បូរណភាពរាងកាយ សិទ្ធិលើទ្រព្យសម្បត្តិ ឬជីវិតឯកជន ដែលនាំឲ្យមានការប្ដឹងទារសំណង ហើយលទ្ធផលនៃការស៊ើបឬឆែក មិនត្រូវទទួលជាភស្តុតាង ដែលជាការចំណាយពេលវេលាកន្លងមក របស់ប៉ូលីស និងមិនសូវមានប្រយោជន៍។

---

29 Dissenting Opinion of Justice Stevens, of Illinois v. Wardlow 528 U.S. 119 (2000) in p.35 of Lore Rutz-Burri, supra note 9។

30 Reid v. Georgia 448 U.S. 438 (1980) in p. 39 of Lore Rutz-Burri, supra note 9។

31 Dissenting Opinion of Justice Stevens, of Illinois v. Wardlow 528 U.S. 119 (2000) in p.36 of Lore Rutz-Burri, supra note 9។

32 ក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧ បានចែងពី វិធានដែលតម្រូវ (mandatory rule) ដែលអាជ្ញាធរត្រូវធ្វើតាម បើមិនដូច្នោះទេ កិច្ចនោះ នឹងត្រូវមោឃៈភាព (មាត្រា ១០៩)។ ជាមួយគ្នានេះដែរ ភាគីអាចស្នើសុំមោឃៈភាពនូវកិច្ចណាមួយបានផងដែរ (មាត្រា ២៧៩ ដល់ ២៨១)។ សូមមើលផងដែរ វិធាន ៧៦ នៃវិធានផ្ទៃក្នុងរបស់ អវតក។

33 សាលដីកាតុលាការកំពូល កម្ពុជា សំណុំរឿងព្រហ្មទណ្ឌសាលដីកាលេខ ២៣៩ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០៣ (ផ្នែកសំអាងហេតុ)។

# បទល្មើសរំលោភសេពសន្ថវៈ

ដោយមេធាវី មាស បូរ៉ា*

## ១. សេចក្តីផ្តើម

ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ បានចែងនូវប្រភេទបទល្មើសជាច្រើន ក្នុងនោះក៏រួមមានបទរំលោភសេពសន្ថវៈ (មាត្រា ២៣៩) បទប្រទូស្តកេរខ្មាស (មាត្រា ២៤៦) បទបង្ហាញកេរ្តិ៍ភេទ (មាត្រា ២៤៩) បទរុកកួនខាងផ្លូវភេទ (មាត្រា ២៥០) និងបទអាសប្រព្រឹត្តទៅលើអនីតិជនអាយុតិចជាង ១៥ឆ្នាំ (មាត្រា ៣៤១)។

ធាតុផ្សំនៃបទល្មើសទាំងនេះ មិនមានភាពច្បាស់លាស់ ដែលអាចនាំឲ្យមានការ ច្រលំ។ អត្ថបទនេះ នឹងមិនលើកយកបទល្មើសទាំងអស់មកប្រៀបធៀបទេ គឺផ្តោតទៅលើបទរំលោភសេពសន្ថវៈ ក្នុងន័យជួយបំភ្លឺបញ្ហាមួយចំនួន ដែលតាមរយៈនេះ គេនឹងអាចមើលឃើញដោយប្រយោលនៃភាពខុសគ្នា នៃបទល្មើសទាំងនេះ។ គំហើញរួម នៃការសិក្សានេះ មិនពេញលេញទាំងស្រុងទេ ដោយសារ មិនមានសាលក្រមកម្ពុជា ដែលអាចត្រូវបានយកមកពិភាក្សាជារួម និងលម្អិត ក្រៅពីការយោងដោយអន្លើៗ។

អត្ថបទចាប់ផ្តើមជាមួយខ្លឹមសាររួម និងចំណុចពាក់ព័ន្ធនៃបទរំលោភសេពសន្ថវៈបន្តដោយការពិភាក្សា អំពីធាតុផ្សំនៃបទល្មើស។ ក្នុងករណី មិនច្បាស់ ការយោងដល់ទ្រឹស្តី ឬយុត្តិសាស្ត្របរទេស នឹងមានជាយថាហេតុ។ ចុងបញ្ចប់អត្ថបទ នឹងពិនិត្យមើលបញ្ហាផ្សេងៗ ដូចជាការដោះសារ និងសង្ខេបជាចុងក្រោយ។

## ២. ខ្លឹមសារ

### ២.១. អត្ថបទច្បាប់

មាត្រា ២៣៩ បានចែងថា៖ គ្រប់អំពើបញ្ចូលអង្គជាត តាមបែបណាក៏ដោយ ឬអំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាត ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នា ឬមិនដូចគ្នា ក៏ដោយ ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយការឆ្មក់

* លោកមេធាវី មាស បូរ៉ា ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលមជ្ឈត្តករពាណិជ្ជកម្ម និងសាស្ត្រាចារ្យច្បាប់។

ឱកាស គឺជាបទរំលោភសេពសន្ថវៈ។ បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ឆ្នាំទៅ ១០ ឆ្នាំ...”។

ក្រៅពីមាត្រានេះ មានមាត្រាចែងពីស្ថានទម្ងន់ ដោយសារការប្រើមធ្យោបាយប្រព្រឹត្ត (មាត្រា ២៤០) ដោយសារជនរងគ្រោះ (មាត្រា ២៤១) ផលវិបាក ដូចជានាំឲ្យមានពិការភាព ( មាត្រា ២៤២) ការធ្វើទារុណកម្មក្នុងពេលប្រព្រឹត្ត (មាត្រា ២៤៣) និង នាំឲ្យជនរងគ្រោះស្លាប់ (មាត្រា ២៤៤)។ បទរំលោភសេពសន្ថវៈ ជាបទឧក្រិដ្ឋ មានទោស ពី៥ ឆ្នាំ ទៅ ១០ ឆ្នាំ។ ក្នុងករណីមានស្ថានទម្ងន់ ទោសអាចមានចន្លោះពី ៧ ឆ្នាំ ដល់ ៣០ ឆ្នាំ។

## ២.២. ធាតុផ្សំនៃបទល្មើស

កាលណាយើងពិនិត្យមើលធាតុផ្សំ មានធាតុនីត្យានុកូល ធាតុសម្ភារៈ និងអត្តនោម័ត។ ធាតុលម្អិតតូចៗ ស្ថិតនៅក្នុងចង្កោមនេះ អាចមានដូចជា៖ អ្នកប្រព្រឹត្ត ជនរងគ្រោះដែលជាមុខសញ្ញា មធ្យោបាយប្រព្រឹត្តជាដើម។

**ធាតុផ្សំសម្ភារៈ**៖ ជាសកម្មភាពដាក់បញ្ចូលអង្គជាត ឬឧបករណ៍ទៅក្នុងអង្គជាត របស់អ្នកដទៃ តាមបែបណាមួយក៏ដោយ ដោយការប្រើហិង្សា។ ក្រមព្រហ្មទណ្ឌ មិនបានផ្តល់និយមន័យនៃពាក្យ “អង្គជាត” ឬ “ឧបករណ៍” ទេ។ ក៏ប៉ុន្តែ តាមន័យធម្មតា អង្គជាត ជាលិង្គ ឬយោនី។ រីឯឧបករណ៍ អាចជា លិង្គសិប្បនិម្មិតជាដើម។[34]

ខ្លឹមសារបុរាណនៃបទរំលោភ គឺទង្វើរបស់បុរស ដាក់បញ្ចូលលិង្គ ក្នុងយោនីរបស់ស្ត្រី ដោយបង្ខំ។ មាត្រា ២៣៩ ផ្តល់ន័យទូលាយ ដោយគ្របនូវការដាក់ឧបករណ៍ ចូលទៅក្នុងអង្គជាត ដូចជា ដាក់លិង្គសិប្បនិម្មិត ចូលក្នុងយោនីជាដើម។ មាត្រានេះ ប្រើពាក្យអាព្យាក្រឹត្យពាក់ព័ន្ធ អ្នកប្រព្រឹត្ត និងជនរងគ្រោះ (អ្នកដទៃ[35])។ ដូចនេះ គេអាចអះអាងថា ជនរងគ្រោះ អាចជាប្រពន្ធ ឬអ្នកណាក៏ដោយ ហើយស្ត្រីក៏អាចជាអ្នកប្រព្រឹត្តដែរ។ ឧទាហរណ៍ នារីម្នាក់ បង្ខំឲ្យបុរសដាក់លិង្គ ចូលក្នុងយោនីរបស់ខ្លួន។[36] ជនរងគ្រោះត្រូវតែជាមនុស្សមានជីវិត។

---

[34] ហ៊ី ធីឫទ្ធិ វចនានុក្រមច្បាប់ ចំពោះបទល្មើសអាជ្ញា ឆ្នាំ ២០១២ ទំ. ៣២០ (ហ៊ីង ធីឫទ្ធិ)។

[35] លើកលែង ពាក្យ “អ្នកដទៃ” សំដៅលើបុគ្គលផ្សេង ក្រៅពីប្តី ឬប្រពន្ធ។

[36] គើត រិទ្ធ ឯកសារជំនួយសម្រាប់ការសិក្សាស្រាវជ្រាវ ស្តីពីបទល្មើសរំលោភសេពសន្ថវៈ ទំ.១០ (មាននៅជាមួយអ្នកនិពន្ធនេះ)។

ប្រសិនបើ ជនប្រព្រឹត្តបានសេពកាមជាមួយខ្មោច វានឹងមានបទចោទផ្សេង (ការបំពានបូរណភាពសាកសព)។[37]

សំណួរសួរថា តើករណីបង្ខំឲ្យធ្វើការរួមភេទដោយមាត់ (oral sex) ជាសកម្មភាពនៃបទរំលោភឬទេ? តាមការបកស្រាយតាមន័យធម្មតានៃពាក្យ "បញ្ចូលក្នុងអង្គជាត" គេមិនអាចថា ជាសកម្មភាពរំលោភទេ ដោយសារមាត់មិនមែនជាអង្គជាតទេ។[38]

ការដាក់បញ្ចូលនូវអង្គជាត ឬឧបករណ៍ ទៅក្នុងអង្គជាត ត្រូវតែមានលក្ខណៈ ហិង្សា ឬគំរាមកំហែង ឬ ឆ្មក់ឱកាស។ ហិង្សាអាចជាការវាយដំលើរូបរាងកាយ ចេញជាស្នាកស្នាមលើរាងកាយជាដើម។[39] ការគំរាមកំហែង អាចជាពាក្យសំដី[40] ឬការព្រមានថានឹងប្រើហិង្សា ប្រសិនបើជនរងគ្រោះមិនព្រមជាមួយការរួមភេទ។ ការឆ្មក់ឱកាស មានក្នុងករណីដែលជនរងគ្រោះ សន្លប់ ហើយជនល្មើសរួមភេទជាមួយ ឬជនរងគ្រោះជាមនុស្សពិការ ដែលមិនអាចតដៃបាន។[41] ប្រសិនបើដូចនេះមែន ការទាមទារ ការតបត ពីជនរងគ្រោះមិនមែនជាកត្តាចម្បង ដើម្បីបង្ហាញ ថាខ្លួនមិនព្រមនោះទេ ។ ហិង្សា ឬការគំរាម វាស្តែងឲ្យឃើញថា ជនរងគ្រោះមិនព្រមនឹងការសេពកាមទេ។[42] ពាក់ព័ន្ធនឹងចំណុចនេះ គេត្រូវចងចាំថា អនីតិជនមិនអាចសំដែងនូវឆន្ទៈថាព្រមក្នុងការរួមភេទទេ។[43]

**ធាតុផ្សំអត្តនោម័តៈ** ខ្លឹមសារមាត្រា ២៣៩ មិនបានបង្ហាញធាតុអត្តនោម័តច្បាស់លាស់ទេ។ ក្រៅពីនេះ នៅមានសំណួរជាច្រើន ដែលមិនមានចម្លើយ ដែលចាំបាច់យោងដល់ យុត្តិសាស្ត្របរទេស ឬអត្ថបទស្រាវជ្រាវ។ សំណួរមួយចំនួនមានដូចជា៖ទី១. តើការគម្រាមកំហែងរាប់បញ្ចូលការគម្រាមដល់ជនទីបី ដូចជា កូន របស់ជនរងគ្រោះ ដើម្បីឲ្យជនរងគ្រោះព្រមរួមភេទ។ ២. តើការនារីច្រលំដេកជាមួយអ្នកដទៃ ស្មានតែជាប្តី អាចជាការអះអាងថា

---

[37] មាត្រា ២៦១ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩។

[38] គេអាចចោទពីបទប្រទូស្តកេរខ្មាស (មាត្រា ២៤៦)។ ទោះបីជាយ៉ាងនេះក្តី ក្នុងសង្គមអឺរ៉ុប គេចាត់ថា មាត់ ជាផ្នែកនៃសកម្មភាពរួមភេទ។

[39] ហ៊ី ធីឫទ្ធិ លេខយោងទី១ ខាងលើ ទំ. ៣២០។

[40] ហ៊ី ធីឫទ្ធិ ដូចខាងលើ ទំ. ៣១៩។

[41] ហ៊ី ធីឫទ្ធិ ដូចខាងលើ ទំ. ៣២១។

[42] ដូចខាងលើ

[43] ក្មេងស្រីអាយុក្រោម ១២ ឆ្នាំ មិនមានសមត្ថភាពផ្តល់ការព្រមព្រៀង ក្នុងការរួមភេទទេ, Gerhard Kemp, South Africa, in p. 229 of Michael Bohlander and Alan Reed, ed., Consent Domestic and Comparative Perspective, 2017.

នាងព្រម នាំឲ្យអ្នកប្រព្រឹត្តរួចខ្លួនពីបទរំលោភដែរឬទេ?។[44] ៣. អ្វីទៅពាក្យ "អង្គជាត"? ៤. តើការព្រមព្រៀងម្តង អាចបន្តការសេពកាម ដែលមិនមែនជាបទរំលោភសេពសន្ថវៈ ទោះបីជនរងគ្រោះដកការព្រមព្រៀងក្នុងអំឡុងពេលនៃការប្រព្រឹត្តក្តី? និងទី ៥. តើមាត្រា ២៣៩ ទាមទារថាការដាក់អង្គជាត ត្រូវតែស៊ីជម្រៅ ឬយ៉ាងណា?។

## ៣. ច្បាប់ យុត្តិសាស្ត្របរទេស និង យោបល់អ្នកជំនាញ

ច្បាប់និងយុត្តិសាស្ត្របរទេស បង្ហាញដូចគ្នា ថាបទរំលោភសេពសន្ថវៈ ជាការសេពកាមដោយបង្ខំ[45] តាមរយៈការដាក់បញ្ចូលនូវអង្គជាត។ អ្នកស្រាវជ្រាវ បានផ្តល់ន័យពាក្យ "អង្គជាត" ក្នុងន័យជាសាមញ្ញ។ សម្រាប់ស្ត្រី វាជាប្រដាប់ភេទ ឬបន្តពូជ[46] អង្គជាត រួមបញ្ចូលរន្ធគូថ ឬមាត់ផងដែរ។[47] សម្រាប់ឧបករណ៍ អាចរួមបញ្ចូល ដប ឬកាំបិត។[48]

យុត្តិសាស្ត្ររបស់ប្រទេស ហ្គាណា ផ្តោតសំខាន់លើ ការដាក់បញ្ចូលអង្គជាត អាស្រ័យហេតុនេះ បានដល់ទីជម្រៅ ឬមិនបាន មិនមែនជាបញ្ហាទេ។[49] បទប្បញ្ញត្តិព្រហ្មទណ្ឌគម្រូ

---

44 សាលក្រមព្រហ្មទណ្ឌលេខ ៥៦៨ តុលាការក្រុងភ្នំពេញ ខែសីហា ឆ្នាំ ២០១៦។

45 ស្ទួត ខូហៀល ពិភាក្សាក្រមព្រហ្មទណ្ឌច្បាប់កម្ពុជា ឆ្នាំ ២០០០ ទំ. ៥២៨។

46 ហ៊ី ធីឫទ្ធិ លេខយោងទី១ ខាងលើ ទំ. ៣២០។ វចនានុក្រមខ្មែរ ដោយ សម្តេចព្រះសង្ឃរាជ ជួន ណាត រកបាននូវគេហទំព័រ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ www.budinst.gov.kh។

47 ស្ទួត ខូហៀល លេខយោងទី១២ ខាងលើ ទំ. ៥២៩។ តាមការបកស្រាយពាក្យ "តាមមធ្យោបាយណាក៏ដោយ", កៅ សីហា នីតិព្រហ្មទណ្ឌពិសេស ឆ្នាំ ២០១៤ ទំ. ៣៧។ សូមមើល ផូវ សំភី ឯកសារជំនួយស្មារតីទី៤ បទរំលោភសេពសន្ថវៈ ទំ.១០ (អ្នកនិពន្ធមានឯកសារនេះ)។ មាត្រា ២៦៦-ក ក្រមព្រហ្មទណ្ឌប្រទេសហ្វីលីពីន ដកស្រង់ក្នុង Leonor D. Roado, Notes and Cases on the Revised Penal Code, 2002, p.539។ Vivenne O'Connor and Colette Rausch, Model Codes for Post-Conflict Criminal Justice, Model Criminal Code, 2007, p. 227។ Kevin Jon Heller and Markus D. Dbber, the Handbook of Comparative Criminal Law, France by Catherine Elliott, 2011, p. 232.

48 ច្បាប់អាមេរិក និងបារាំង យោងក្នុង លេខយោងទី ១០, ស្ទួត ខូហៀល លេខយោងទី១២ ខាងលើ ទំ. ៥២៩។ កើត រិទ្ធ លេខយោងទី៣ ខាងលើ ទំ.១០។ Kevin Jon Heller, France by Catherine Elliott, លេខយោងខាងលើ p. 232.

49 R v. Marsden (1890 -95) 17 CoX CC 297 ដកស្រង់ក្នុងសៀវភៅ Henrierra J.A.N. Mensa-Bonsu, the Annotated Criminal Code of Ghana, 1999, ទំ. ៩៨។ Leonor D. Roado, លេខយោងទី១៤ ខាងលើ p.555

ដែលជាសមិទ្ធផលនៃការងាររបស់អ្នកតំណាងរដ្ឋ ហើយដែលបានឯកភាពលើខ្លឹមសារ មិនសំខាន់លើទីជម្រៅនៃការដាក់បញ្ចូលអង្គជាតទេ។[50]

បទរំលោភសេពសន្ថវៈ ក៏អាចធ្វើឡើងដោយប្តីលើប្រពន្ធខ្លួនឯងផងដែរ[51]។ ក៏ប៉ុន្តែប្រទេសខ្លះ មិនចាត់ថាជាបទល្មើសប្រភេទនេះទេ គឺចាត់ចូលក្នុងប្រភេទបទល្មើសផ្សេង។[52]

សកម្មភាពបង្ហាញតាមរយៈការប្រើហិង្សា ជាដើម ដើម្បីជនរងគ្រោះបង្ខំចិត្តព្រមតាម។ ហិង្សា អាចធ្វើចំពោះអ្នកទីបី ដូចជាឪពុក ដើម្បីបង្ខំកូនស្រី។[53] ការគំរាម ឬបង្ខំ មិនត្រូវបានតម្រូវជាចំបងទេ។ ទោះបី ជាយ៉ាងនេះក្តី ក្នុងករណីខ្លះ វាទាមទារឲ្យមានការ បង្ហាញពីការតបទល់ (resisting)[54] ឬការសំដែង ការជំទាស់ច្បាស់លាស់ (express)[55]។ វាមិនតម្រូវឲ្យមានការជំទាស់ រហូតដល់ជនរងគ្រោះអស់កំលាំងទេ។ ការទាមទារដូចនេះ នឹងមិនអនុវត្តបានក្នុងករណី ការរំលោភបូក ដែលក្នុងនាទីចុងក្រោយ ស្ត្រីរងគ្រោះ បាក់កំលាំង មិនអាចតទល់បាន។[56] ការណ៍ដែល ជនល្មើសមានមាឌធំ មិនមែនជាការដោះសារ ដោយជនរងគ្រោះ ថាមិនតបតទេ។[57]

ក្នុងករណីខ្លះ ការមិនតបត អាចបណ្តាលមកពីការច្រឡំ។ ស្ត្រីបានព្រមដេកជាមួយបុរស ក្នុងពេលយប់ ដោយស្មានថា បុរសនោះជាប្តី។ ប្រសិនបើការច្រឡំនោះពិតប្រាកដ ការព្រមព្រៀងនេះ មិនត្រូវបដិសេធទេ។ ទោះបីជាយ៉ាងណាក្តី ប្រសិនបើដឹងថា បុរសនោះមិនមែនជាប្តីរបស់នាង នាងនឹងមិនដេកជាមួយទេ។ វានឹងនៅតែជាបទរំលោភ ហើយបុរស មិន

[50] Vivenne O'Connor and Colette Rausch, លេខយោងទី១៤, p. 227.

[51] ស្នួត ខូហៀល លេខយោងទី១២ ខាងលើ ទំ. ៥២៩។ John L. Gibson, Canadian Criminal Code Offences, 1993, ទំ. ៤៨-១៦។ Vivenne O'Connor and Colette Rausch, លេខយោងទី១៤ ខាងលើ, p. 228. Kevin Jon Heller and Markus D. Dbber, លេខយោងទី១៤ ខាងលើ, p. 232 (គេសន្មត់ថា ប្រពន្ធព្រមនូវការរួមភេទ នេះគឺជាការសន្មត់ ដែលអាចត្រូវបានបដិសេធដោយភស្តុតាងផ្ទុយ។ ករណីចោទប្រកាន់ប្តីរំលោភប្រពន្ធ ជាករណីលើកលែងពិសេស)។.

[52] ហ៊ី ធីឬទ្ធិ លេខយោងទី១ ខាងលើ ទំ. ៣២២ ។ កើត រិទ្ធ លេខយោងទី៣ ខាងលើ ទំ. ១៤។

[53] កើត រិទ្ធ លេខយោងទី៣ ខាងលើ ទំ. ១១។

[54] ហ៊ី ធីឬទ្ធិ លេខយោងទី១ខាងលើ ទំ. ៣២១។ ទោះបីជាយ៉ាងនេះក្តី គេមិនទាមទារនូវភស្តុតាង បញ្ជាក់ថាបានតបតទេ សូមមើល Michael Bohlander, Principles of German Criminal Law, 2009, ទំ. ២០១។

[55] Joshua Dressler, Understanding Criminal Law, 2009, pp. 589, 590.

[56] កម្រិតគំរាមគំហែងខ្លាំងក៏មិនទាមទារដែរ, Leonor D. Roado, លេខយោងទី១៤ ខាងលើ, pp.550, 554។

[57] Joshua Dressler លេខយោងទី២២ ខាងលើ, pp. 587, 588.

អាចអះអាងថាស្មានតែនាងព្រម ក្នុងករណីអ្នកប្រព្រឹត្តមានចេតនា ឬល្បិច ដូចជាស្លៀកសំលៀកបំពាក់ ឬប្រើទឹកអប់ ដូចប្តី ដែលធ្វើឲ្យនាងច្រឡំ។

ក្រៅពីករណីដែលជនរងគ្រោះជាអនីតិជន ឬស្ថិតក្នុងស្ថានភាព មិនអាចផ្តល់ការព្រមព្រៀងដោយពិតប្រាកដ រួមទាំងការមិនតដៃ អ្នកប្រព្រឹត្តអាចអះអាង ថានាងព្រម ទើបបានជាខ្លួនប្រព្រឹត្ត។ ដើម្បីបង្ហាការព្រមព្រៀងរួមភេទ ទៅជាបទរំលោភ ច្បាប់ និងយុត្តិសាស្ត្រ ទាមទារឲ្យជនល្មើសសួរបញ្ជាក់ ជនរងគ្រោះថាព្រមឬទេ ឬមានអាយុប៉ុន្មាន?[58] អង្គហេតុក្នុងផ្នែកនេះជាការច្រឡំអង្គហេតុ (mistake of fact)។[59] វាអាចនឹងទទួលឲ្យរួមផុតពីការទទួលខុសត្រូវ ប្រសិនបើជាការច្រឡំដោយស្មោះត្រង់ និងមានហេតុផល (honest and reasonable mistake)។[60]

គូសង្សារធ្លាប់សេពកាមជាញយដងមកហើយជាមួយគ្នា។ នៅក្នុងពេលមួយ នាងមិនព្រម ហើយសង្សារនៅតែបង្ខំ វានឹងជាបទរំលោភ។ ដូចនេះ ការព្រមឬមិនព្រៀង គឺអនុវត្តកំពុងសេពកាម ដើម្បីកំណត់ថា ជាបទល្មើសរំលោភសេពសន្ថវៈឬមិនមែន។[61] ស្រដៀងគ្នានេះដែរនាអំឡុងពេលសេពកាម វាអាចកើតមានករណី ដែលនាងបានព្រមពីដំបូង បន្តិចក្រោយមកនាងដកការព្រមព្រៀង ក៏ប៉ុន្តែ បុរសនៅតែប្រព្រឹត្ត។ យុត្តិសាស្ត្របរទេស បង្ហាញ នូវជំហរចំនួនពីរ។ ទី១. ករណីដែល ជនល្មើសនៅបន្ត ជនល្មើស អាចនឹងទទួលខុសត្រូវចំពោះបទល្មើសហិង្សា (Battery) តែមិនមែនបទល្មើសរំលោភសេពសន្ថវៈ។[62] ខ្លះនៅតែរក្សាថា វានៅតែជាអំពើរំលោភសន្ថវៈ។[63] តុលាការអះអាងថា៖ ការរួមភេទ ជាកិច្ចបន្ត ដែលបញ្ចប់ ពេលដកចេញតែប៉ុណ្ណោះ។ ដូចនេះ ការមិនដកចេញ ជនល្មើសមានទោសពីបទរំលោភសេពសន្ថវៈ។[64] ករណីខាងក្រោយ វាអាចអាស្រ័យទៅលើច្បាប់ ឬយុត្តិសាស្ត្រផងដែរ ដែលទាមទារឲ្យដាក់

---

[58] ច្រឡំអាយុ មិនមែនជាការដោះសារទេ លើកលែងជនល្មើស បានសួរបញ្ជាក់អំពីអាយុនៃជនរងគ្រោះ Canadian Criminal Offense, លេខយោងទី១៨ ខាងលើ ទំ.43-4។

[59] មិនអាចលើកការច្រឡំថា គេព្រមទេ ក្នុងករណីអនីតិជនអាយុក្រោម ១៤ ឆ្នាំ សូមមើល លេខយោងខាងលើ, ទំ. ៥៤-៣៨។

[60] Joshua Dressler លេខយោងទី២២ ខាងលើទំ.158។

[61] ហ៊ី ធីឫទ្ធិ លេខយោងទី១ ខាងលើ ទំ. ៣២១។

[62] Joshua Dressler លេខយោងទី២២ ខាងលើ ទំ. 587។

[63] Kai Ambos and Stefanie Bock, Germany in p.277-278 of Michael Bohlander and Alan Reed, ed., Consent Domestic and Comparative Perspective, 2017.

[64] The Appellant discovered after penetration that the woman was no longer consenting. He, however, did not desist from the intercourse. He was held to have raped her. The court stated that, "sexual intercourse is a continuing act which ends only in withdrawal." In not desisting therefore, the appellant had been held properly convicted of rape, Kaitamaki v. R (1984] 3 WLR 137, PC in p. 97 of Henrierra J.A.N. Mensa-Bonsu, the Annotated Criminal Code of Ghana, 1999,

បញ្ចូលអង្គជាតិចូលរួចរាល់ ទោះជ្រៅឬ រាក់ក្តី។ ក៏ប៉ុន្តែ បើមិនទាន់បញ្ចូលទេ ក៏មិនអាចជាបទរំលោភសេពសន្ថវៈដែរ។ វានៅជាបទប៉ុនប៉ងរំលោភ[65] ឬ បទប្រទូស្តកេរភេទជាដើម។

បទរំលោភ ជាបទល្មើសដែលមានធាតុផ្សំចេតនាទូទៅ (General-Intent- Offence)[66]។ អាស្រ័យហេតុនេះ ជនល្មើសដឹងថា ការបង្ខំសេពកាម ជាទង្វើខុសច្បាប់ហើយ នៅតែប្រព្រឹត្ត គឺទទួលខុសត្រូវហើយ។ គេមិនខ្វល់ថា ជនល្មើសមាន មូលហេតុ (motive) ឬគោលបំណងអ្វីទេ។[67] ភ្ជាប់គ្នានឹងខ្លឹមសារ ខាងលើ ធាតុអត្តនោម័ត គឺការដឹងថា ជនរងគ្រោះមិនព្រម តែអ្នកប្រព្រឹត្តនៅតែ ចាប់បង្ខំសេពសន្ថវៈ។

## ៤. សង្ខេប

ក្រោយពីការពិនិត្យមើលអត្ថបទ ខ្លឹមសារ បទរំលោភសេពសន្ថវៈ ប្រព្រឹត្តឡើងដោយជនណាមួយ រាប់ទាំងប្តី មិនថាស្ត្រីឬប្រុស លើជនរងគ្រោះ ស្ត្រី (ជាប្រពន្ធ) ឬប្រុស ដោយប្រើហិង្សាជាដើម ដោយការដាក់អង្គជាតទៅក្នុងអង្គជាត។ វាមិនសំខាន់ថា ដាក់ចូលអង្គជាតជ្រៅ ឬរាក់កម្រិតណាទេ។ ការផ្តល់ព្រមព្រៀងអំឡុងពេលនៃការសេពកាម ត្រូវមានជាបន្ត ហេតុនេះ ប្រសិនបើជនរងគ្រោះ ឈប់ព្រម ហើយជនប្រព្រឹត្តនៅតែបន្ត អាចនឹងមានទោសពីបទរំលោភ ឬបទល្មើសផ្សេងទៀតទៅតាមយុត្តិសាស្ត្ររបស់ប្រទេសនីមួយៗ។ នៅមានបញ្ហាមួយចំនួនមិនទាន់ត្រូវបានបកស្រាយច្បាស់លាស់ ដែលទាមទារឲ្យមានការសិក្សាបន្ត ដូចជាថា៖ តើតាមច្បាប់កម្ពុជា សកម្មភាពសេពកាមតាមមាត់ ជាអំពើរំលោភសេពសន្ថវៈដែរឬទេ?។ បន្ថែមពីលើនេះ តើអ្វីទៅជាការប៉ុនប៉ងរំលោភសេពសន្ថវៈ។

---

[65] អង្គហេតុនៃបទប៉ុនប៉ងរំលោភ៖ រងគ្រោះត្រូវបានផ្តួល ឬអាវរហែក ទ្រូងចេញដោះ សូមមើល Leonor D. Roado, លេខយោងទី១៤ ខាងលើ, p.553។ អង្អែលទ្រូង និងដាក់ស្រោមអនាម័យ គឺចាប់ផ្តើមរំលោភហើយ សូមមើល អត្ថបទដោយ កើត រិទ្ធ លេខយោងទី៣ ខាងលើ ទំ. ១៦។ ករណី ចោទប្រទូស្តកេរខ្មាស ជំនួសប៉ុនប៉ងរំលោភ មិនសមស្របទេ ពីព្រោះកម្រិត ទោសផ្សេងគ្នា។ប៉ុនប៉ងរំលោភ នៅតែជាបទឧក្រិដ្ឋ តែបទប្រទូស្តកេរខ្មាស ជាបទមជ្ឈិម, សូមមើល អត្ថបទដោយ ផូវ សំភី លេខយោងទី១៤ ខាងលើ ទំ.១០។

[66] ស្ទួត ខូហៀល លេខយោងទី ១២ខាងលើ ទំ. ៥៣២។ Kevin Jon Heller and Markus D. Dbber, លេខយោងទី ១៤ ខាងលើ p. 232

[67] Kevin Jon Heller and Markus D. Dbber, លេខយោងទី១៤ខាងលើ p. 232។

# ច្បាប់ បរធនបាលកិច្ចនៅកម្ពុជា

# ច្បាប់ បរធនបាលកិច្ចនៅកម្ពុជា

## ដោយមេធាវី គង់ សំអុន*

## ១. គោលការណ៍ទូទៅ

### ១.១. និយមន័យ

បរធនបាល គឺជាទំនាក់ទំនងរវាងបីភាគី ដែលមាន (១)បរធនបាលទាយក (២)បរធនបាល និង(៣)អត្ថគាហកៈ ក្នុងការផ្ទេរ(ទ្រព្យសម្បត្តិ ឬមូលនិធិ) ដើម្បីជាផលប្រយោជន៍ដល់អត្ថគាហកៈ ហើយក៏អាចមាន ភាគីផ្សេងទៀត ជាអ្នកផ្តល់វិភាគទានបរធនបាលកិច្ច និងបរធនបាលទាយកជំនួស។ បរធនបាល គឺជា ម្ចាស់កម្មសិទ្ធិស្របច្បាប់នៃទ្រព្យសម្បត្តិ ដែលមានថែងក្នុងបរធនបាលកិច្ច ហើយមានកាតព្វកិច្ចក្នុងការរក្សានូវផលប្រយោជន៍សម្រាប់អត្ថគាហកៈ ដែលបរធនបាលមានសិទ្ធិពេញលេញក្នុងការចាត់ចែងទ្រព្យសម្រាប់ផ្តល់ផលប្រយោជន៍ដល់អ្នកត្រូវទទួលបាននូវប្រយោជន៍។

### ១.២. គោលបំណង

ច្បាប់ស្តីពី បរធនបាលកិច្ច មានគោលបំណងគ្រប់គ្រងបរធនបាល ដែលត្រូវបានបង្កើតឡើងក្នុងព្រះរាជាណាចក្រកម្ពុជា។ ច្បាប់នេះ គឺជាវិភាគទានថ្មីមួយ នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ដែលជាការនាំចូលពីបណ្តាប្រទេសគ្រប់គ្រងដោយប្រព័ន្ធច្បាប់ Common Law ដូចជាប្រទេសអង់គ្លេស សហរដ្ឋអាមេរិក ជាដើម។ ទោះជាយ៉ាងណាក្តី នៅក្នុងបណ្តាប្រទេសដែលគ្រប់គ្រងដោយប្រព័ន្ធច្បាប់Civil Law មួយចំនួនក៏បានបញ្ជ្រាបច្បាប់ បរធនបាលកិច្ចនេះ ក្នុងក្រមរដ្ឋប្បវេណីរបស់ប្រទេសខ្លួនផងដែរ ដូចជាប្រទេសបារាំង ជាដើម។

### ១.៣. ដំណើរការអនុម័ត និងភាពចាំបាច់

ការបង្កើតច្បាប់ស្តីពី បរធនបាលកិច្ចនេះ ដោយហេតុថា រាជរដ្ឋាភិបាលកម្ពុជាបានប្រមើលឃើញពីការអភិវឌ្ឍ និងការរីកចំរើនសេដ្ឋកិច្ចរបស់ប្រទេសជាតិ ដើម្បីជួយពង្រឹងដល់ការគ្រប់គ្រង និងតាមដានត្រួតពិនិត្យ វិស័យបរធនបាលកិច្ចប្រកបដោយប្រសិទ្ធភាព និងតម្លាភាព

---

* លោកមេធាវី គង់ សំអុន ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

ដែលកម្ពុជាត្រូវការចាំបាច់សម្រាប់គ្រប់គ្រងទ្រព្យសម្បត្តិស្របតាមច្បាប់ និងប្រកបដោយសមធម៌។ក្នុងន័យនេះសក្តានុពលនៃការរីកចំរើនសេដ្ឋកិច្ចនៅកម្ពុជា ដែលកំពុងនាំឱ្យប្រជារាស្ត្រខ្មែរមួយចំនួនមានទ្រព្យសម្បត្តិ ហើយមិនចង់គ្រប់គ្រងផ្ទាល់ដោយខ្លួនឯង និងដែលមានបំណងចង់បានការគ្រប់គ្រងស្របច្បាប់មួយលើទ្រព្យសម្បត្តិប្រកដដោយចីរភាព និងមានការទទួលខុសត្រូវតាមវិជ្ជាជីវៈបរធនបាល ដែលកម្ពុជាកំពុងដំណើរការអភិវឌ្ឍក្នុងរយៈពេលជាងបីទសវត្សមកនេះ ទាំងរូបវន្តបុគ្គល និងនីតិបុគ្គលពាណិជ្ជកម្មមានភាពចាស់ទុំ។

យោងតាម ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាម្ចាស់ពង្រាងច្បាប់នេះ បានលើកឡើងក្នុងសម័យប្រជុំលើកទី២ ព្រឹទ្ធសភា នីតិកាលទី៤ នាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ ថាច្បាប់ស្តីពី បរធនបាលកិច្ច គឺជាវិស័យហិរញ្ញវត្ថុថ្មីមួយ សម្រាប់ព្រះរាជាណាចក្រកម្ពុជា ហើយវិស័យមួយនេះ នឹងរួមចំណែកដល់ការអភិវឌ្ឍវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសង្គមកម្ពុជា ឱ្យកាន់តែមានសភាពជឿនលឿនពិពិធកម្ម ឆ្លើយតបទៅនឹងបរិបទថ្មីៗ នៃវិស័យហិរញ្ញវត្ថុសកល ដើម្បីជាការធានា និងទាក់ទាញនូវភាពជឿទុកចិត្តពីដៃគូអភិវឌ្ឍន៍នានា។

ម៉្យាងទៀត សេចក្តីប្រកាសពត៌មានស្តីពី **លទ្ធផលនៃការបន្តសម័យប្រជុំលើកទី២ ព្រឹទ្ធសភា នីតិកាលទី៤ នាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨** ច្បាប់នេះ រៀបចំឡើងក្នុងគោលបំណងគ្រប់គ្រងមូលនិធិហិរញ្ញប្បទានឥតសំណង ឬអនុបំណុល ដែលផ្តល់ដោយដៃគូរអភិវឌ្ឍន៍ ដើម្បីគាំទ្រដល់វិស័យមីក្រូហិរញ្ញវត្ថុ ហើយបច្ចុប្បន្នមូលនិធិទាំងនេះ កំពុងគ្រប់គ្រង និងចាត់ចែងប្រើប្រាស់ដោយគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុមួយចំនួន។ ដោយពិនិត្យឃើញនូវភាពចាំបាច់នៃវិសាលភាពទូលំទូលាយ ក្នុងវិស័យបរធនបាលកិច្ច ដែលមិនត្រឹមតែគ្របដណ្តប់លើវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុប៉ុណ្ណោះទេ វិស័យនេះមានវិសាលភាពគ្របដណ្តប់លើវិស័យធានារ៉ាប់រង និងសោធន វិស័យអចលនទ្រព្យ វិស័យមូលបត្រ និងវិស័យនេះមានវិសាលភាពផ្សេងៗទៀតនៅក្នុងសេដ្ឋកិច្ច និងសង្គមផងដែរ។ គុណប្រយោជន៍នៃច្បាប់នេះ រួមមាន (១)បង្កើនការវិនិយោគក្នុងស្រុក ដែលជាប្រភពនៃការបន្ថែមចំណូលពន្ធជាតិ (២)ជំរុញការធ្វើពិពិធកម្មហិរញ្ញវត្ថុ ដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជា និង (៣)ផ្តល់លទ្ធភាពដល់ការតាមដាន និងគ្រប់គ្រងនូវលំហូរទុន និងប្រភពទុនលើគ្រប់វិស័យដែលកំពុងធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅទាក់ទាញទំនុកចិត្តបន្ថែមពីដៃគូរអភិវឌ្ឍន៍នានា។

## ២.រចនាសម្ព័ន្ធ

ច្បាប់ស្តីពី បរធនបាលកិច្ចរបស់កម្ពុជា ត្រូវបានបែងចែកជា ៨ ជំពូក មាន ៥៧ មាត្រាៈ

- ❖ ជំពូកទី១. បទប្បញ្ញត្តិទូទៅ
- ❖ ជំពូកទី២. បរធនបាលកិច្ច
- ❖ ជំពូកទី៣. បរធនបាលទាយក បរធនបាល និងអត្ថគាហកៈ
- ❖ ជំពូកទី៤. ការចុះបញ្ជីបរធន ការត្រួតពិនិត្យ និងការបញ្ចប់បរធនបាលកិច្ច
- ❖ ជំពូកទី៥. ការដោះស្រាយវិវាទ និងការធ្វើអធិការកិច្ច
- ❖ ជំពូកទី៦. ទោសប្បញ្ញត្តិ
- ❖ ជំពូកទី៧. អន្តរប្បញ្ញត្តិ
- ❖ ជំពូកទី៨. អវសានប្បញ្ញត្តិ

### ២.១. ជំពូកទី១ បទប្បញ្ញត្តិទូទៅ

ជំពូកនេះ បែងចែកចេញជា ៤ មាត្រា ដែលមានដូចជា (១)គោលបំណងគ្រប់គ្រងបរធនដែលត្រូវបានបង្កើតឡើងក្នុងព្រះរាជាណាចក្រកម្ពុជា (២)គោលដៅកំណត់អំពីវិធាន នីតិវិធីនៃការបង្កើត ការចុះបញ្ជី ការគ្រប់គ្រង និងការត្រួតពិនិត្យ បរធនបាលកិច្ច (៣)វិសាលភាពអនុវត្តចំពោះបរធនបាលកិច្ចដែលបានបង្កើតក្នុងព្រះរាជាណាចក្រកម្ពុជានិង(៤)និយមន័យត្រូវបានកំណត់ក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

### ២.២. ជំពូកទី២ បរធនបាលកិច្ច

ជំពូកនេះ បែងចែកចេញជា ១២ មាត្រា ហើយផ្តោតទៅលើ ៣ ផ្នែកសំខាន់ៗគឺៈ

- ❖ ផ្នែកទី១. ភាគី ការបង្កើត និងអានុភាពនៃបរធនបាលកិច្ចៈ ការបង្កើតបរធនបាលកិច្ចត្រូវមានតួអង្គបីជាចាំបាច់មានដូចជា បរធនបាលទាយក បរធនបាល និងអត្ថគាហកៈ និងអាចមានតួអង្គផ្សេងទៀតទៅតាមប្រភេទនៃ បរធនបាលកិច្ចដូចជា អ្នកផ្តល់វិភាគទានបរធនបាលកិច្ច និងបរធនបាលទាយកជំនួស។
- ❖ ផ្នែកទី២. គោលបំណងនៃបរធនបាលកិច្ច (១)បរធនបាលកិច្ចពាណិជ្ជកម្ម ត្រូវបានបង្កើតឡើងក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ សម្រាប់ជាប្រយោជន៍

ដល់អ្នកផ្តល់វិភាគទានបរធនបាល កិច្ច ឬ បុគ្គលណាមួយជាក់លាក់ដែលកំណត់ដោយអ្នកផ្តល់វិភាគទានបរធនបាលកិច្ច ដូចជា មូលនិធិសោធននិវត្តន៍ មូលនិធិអប់រំ និង មូលនិធិប្រហាក់ប្រហែលផ្សេងទៀត (២)បរធនបាលកិច្ចសាធារណៈ ត្រូវបានបង្កើតឡើងក្នុងគោលបំណងសម្រាប់ជាប្រយោជន៍ របស់ប្រជាពលរដ្ឋខ្មែរទូទៅដូចជា ការអភិវឌ្ឍវិស័យធានាគារ និងមីក្រូហិរញ្ញវត្ថុ និងការការពារមូលនិធិតាមលក្ខខណ្ឌផ្សេងៗរួមមាន មូលនិធិដែលបានផ្តល់ឱ្យរាជរដ្ឋាភិបាល ពីភាគីអ្នកផ្តល់ជំនួយ ឬមូលនិធិដែលផ្តល់ដោយរាជរដ្ឋាភិបាលទៅបរធនបាល ដើម្បីចាត់ចែង និងប្រើប្រាស់ជាប្រយោជន៍ដល់អត្ថគាហកៈ (៣)បរធនបាលកិច្ចសង្គម ត្រូវបានបង្កើតឡើងតាមរយៈការធ្វើប្រទានកម្មទ្រព្យសម្បត្តិ របស់បរធនបាល ទាយកឱ្យទៅបរធនបាល ក្នុងគោលបំណងជាប្រយោជន៍ទូទៅដល់សង្គមរួមមាន វប្បធម៌ អប់រំមនុស្សជាតិ សាសនា និងវិទ្យាសាស្ត្រ (៤)បរធនបាលកិច្ចបុគ្គល ត្រូវបានបង្កើតឡើងតាមរយៈការធ្វើប្រទានកម្ម ឬមរតកសាសន៍សម្រាប់ជាប្រយោជន៍របស់បរធនបាលទាយកខ្លួនឯងផ្ទាល់ ឬបុគ្គលណាមួយដែលបានកំណត់ជាក់លាក់ ដោយបរធនបាលទាយក។

- ផ្នែកទី៣. ការកែប្រែគោលបំណង និងរយៈពេលនៃបរធនបាលកិច្ចមាន៖ បរធនបាល អាចស្នើសុំកែប្រែគោលបំណងបរធនបាលកិច្ចទៅបញ្ញត្តិករពាក់ព័ន្ធ និងជូនដំណឹងមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រយៈពេលនៃបរធនបាលកិច្ចនីមួយៗត្រូវកំណត់ក្នុងលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។

## ២.៣. ជំពូកទី៣ បរធនបាលទាយក បរធនបាល អត្ថគាហកៈ

ជំពូកនេះ បែងចែកចេញជា ១១ មាត្រា ហើយផ្តោតលើ ៣ ផ្នែកសំខាន់ៗគឺ៖

- ផ្នែកទី១. បរធនបាលទាយក សំដៅដល់បុគ្គល ដែលបង្កើត និងកំណត់លក្ខខណ្ឌនៃបរធនបាលកិច្ច និងផ្តល់ទ្រព្យសម្បត្តិ ឬមូលនិធិដំបូង ទៅក្នុងលិខិតបរធនបាលកិច្ច។

- ផ្នែកទី២. បរធនបាល សំដៅដល់បុគ្គល ដែលទទួលសិទ្ធិគ្រប់គ្រងនិងចាត់ចែង បរធន ពីបរធនបាលទាយក សម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។
- ផ្នែកទី៣. អត្ថគាហកៈ សំដៅដល់បុគ្គលដែលទទួលផលប្រយោជន៍ពីបរធនបាលកិច្ច។ ក្រៅពីនេះ ក៏បានលើកឡើងពីសិទ្ធិរបស់បរធនបាលទាយក បរធបាល និង អត្ថាគាហកៈ។

## ២.៤. ជំពូកទី៤ ការចុះបញ្ជីបរធនបាល ការត្រួតពិនិត្យ និងការបញ្ចប់បរធនបាល

ជំពូកនេះ បែងចែកចេញជា ០៦ មាត្រា ហើយផ្តោតលើ ២ ផ្នែកសំខាន់ៗគឺ៖

- ផ្នែកទី១. ការចុះបញ្ជីបរធន បរធនបាលកិច្ចទាំងអស់មានសុពលភាព លុះត្រាតែចុះបញ្ជីនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេលមិនលើសពី ៣ (បី) ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការបង្កើត បរធនបាលកិច្ច។
- ផ្នែកទី២. ការត្រួតពិនិត្យ និងការបញ្ចប់បរធនបាលកិច្ច៖ រាល់ប្រតិបត្តិការនៃបរធនបាលកិច្ច ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់បញ្ញត្តិករពាក់ព័ន្ធ ដើម្បីការពារការប្រើប្រាស់បរធនឱ្យស្របតាមគោលបំណងបរធនបាលកិច្ច។ បរធនបាលកិច្ចត្រូវបានបញ្ចប់ ក្នុងករណីមានជាអាទិ៍ ការមកដល់នៃកាលាវសានដែលកំណត់នៅក្នុងលិខិតបរធនបាលកិច្ច និងសម្រេចតាមគោលបំណងរបស់បរធនបាលកិច្ច ការសម្រេចដោយឆន្ទានុសិទ្ធិ ឬមតិជាឯកឆន្ទរបស់បរធនបាលទាយក តាមសេចក្តីសម្រេចរបស់តុលាការមានសមត្ថកិច្ច ឬតាមករណីផ្សេងទៀតដូចមានចែងក្នុងលិខិតបរធនបាលកិច្ច។

## ២.៥. ជំពូកទី៥ ការដោះស្រាយវិវាទ និងការចុះអធិការកិច្ច

ជំពូកនេះ បែងចែកចេញជា ០៩ មាត្រា ហើយផ្តោតលើ ២ ផ្នែកសំខាន់ៗគឺ៖

- ផ្នែកទី១. ការដោះស្រាយវិវាទ៖ វិវាទពាក់ព័ន្ធនឹងប្រតិបត្តិការនៃបរធនបាលកិច្ចត្រូវដោះស្រាយដោយក្រុមប្រឹក្សាដោះស្រាយវិវាទបរធនបាលកិច្ចនៃក្រសួងសេដ្ឋ

កិច្ច និងហិរញ្ញវត្ថុ លើកលែងតែមានការកំណត់ផ្សេងដោយបញ្ញត្តិករពាក់ព័ន្ធ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយវិវាទ ជាកម្មវត្ថុនៃបណ្តឹងរដ្ឋបាល ឬបណ្តឹងតវ៉ាទៅតុលាការ មានសមត្ថកិច្ចក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃចេញសេចក្តីសម្រេច។

- ផ្នែកទី២. ការធ្វើអធិការកិច្ច៖ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិចាត់តាំងមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ដើម្បីតាមដាន ស្រាវជ្រាវ ត្រួតពិនិត្យ និងជំរុញការអនុវត្តច្បាប់នេះ។

## ២.៦. ជំពូកទី៦ ទោសប្បញ្ញត្តិ

ជំពូកនេះ បែងចែកចេញជា ១១ មាត្រា។ ហើយច្បាប់ស្តីពី បរធនបាលកិច្ច បានកំណត់អំពីបទល្មើសក្នុងការផាកពិន័យមួយចំនួនដូចជា ការខកខានមិនបានមកស្នើសុំចុះបញ្ជីបរធនបាលកិច្ច មិនបានរាយការណ៍ និងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងឱ្យភាគីពាក់ព័ន្ធ មិនបានផ្តល់របាយការណ៍ហិរញ្ញវត្ថុទៅបញ្ញត្តិករពាក់ព័ន្ធ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌមួយចំនួនដូចជា បទល្មើសរំលោភលើទំនុកចិត្ត បទល្មើសឆបោក រារាំងឬជ្រៀតជ្រែកដល់មន្ត្រីអធិការកិច្ច និងក្លែងបន្លំឯកសារ ជាដើម។

## ២.៧. ជំពូកទី៧ អន្តរប្បញ្ញត្តិ

ជំពូកនេះ មាន ១ មាត្រា តម្រូវឱ្យបុគ្គលដែលបាននិងកំពុងគ្រប់គ្រងបរធនបាលកិច្ច ត្រូវមកចុះបញ្ជី ដូចមានចែងក្នុងមាត្រា២៨ នៃច្បាប់នេះ។

## ២.៨. ជំពូកទី៨ អវសានប្បញ្ញត្តិ

ជំពូកនេះ បែងចែកចេញ ៣ មាត្រា ហើយបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

## ៣. បទពិសោធន៍ និងការអនុវត្តនៅបរទេស

### ៣.១. ការអនុវត្តនៅបណ្តាប្រទេសប្រើប្រព័ន្ធច្បាប់ Common Law

នៅបណ្តាប្រទេសដែលប្រើប្រព័ន្ធច្បាប់ Common Law ដូចជា ប្រទេសអង់គ្លេស សហរដ្ឋអាមេរិក ជាអាទិ៍ បរធនបាលកិច្ច អាចត្រូវបានបង្កើតឡើងទាំងបុគ្គលដែលមានជីវិត និងបុគ្គលដែលបានទទួលមរណៈភាព ហើយដែលបរធនបាលមានកាតព្វកិច្ច និងការទទួលខុសត្រូវ ចំពោះបរធនបាលទាយក និងអត្ថគាហកៈនូវសកម្មភាពរបស់ខ្លួនជាមួយភាគីផ្សេងទៀត។ យោងតាមអនុសញ្ញាទីក្រុងឡាអេ (១ កក្កដា ១៩៨៥) ស្តីពីច្បាប់អនុវត្តសម្រាប់បរធនបាលកិច្ច និងការទទួលស្គាល់បរធនបាលកិច្ច។ បរធនបាលត្រូវបានបង្កើតឡើងដោយដោយសេចក្តីសម្រេចរបស់តុលាការ ដែលជាយុត្តិសាស្ត្រ (Doctrine) នៅក្នុងប្រព័ន្ធច្បាប់ Common Law ហើយដែលអាចកែប្រែទៅតាមការវិវត្ត នៃវិស័យច្បាប់នោះ។ គេបានរកឃើញគោលការណ៍ជាច្រើន នៅក្នុងប្រព័ន្ធច្បាប់របស់ប្រទេសអង់គ្លេស និង សហរដ្ឋអាមេរិកទាក់ទងទៅនឹងការគ្រប់គ្រងទ្រព្យសម្បត្តិស៊ីវិល។

### ៣.២. ការអនុវត្តនៅបណ្តាប្រទេសប្រើប្រព័ន្ធច្បាប់ Civil Law

ចំពោះនៅបណ្តាប្រទេសដែលប្រើប្រព័ន្ធច្បាប់ Civil Law ដូចជា ប្រទេសកម្ពុជា ប្រទេសឥណ្ឌូនេស៊ី ប្រទេសឡាវ ប្រទេសថៃ ប្រទេសវៀតណាម ជាដើម បរធបាលកិច្ច ក្នុងគោលបំណងរួមចំនែកដល់ការអភិវឌ្ឍន៍ វិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសង្គមឱ្យកាន់តែមានភាពជឿនលឿន ឆ្លើយតបនឹងបរិបទថ្មីៗ នៃវិស័យហិរញ្ញវត្ថុសកល ដើម្បីជាការធានា និងទាក់ទាញនូវភាពទុកចិត្តពីដៃគូអភិវឌ្ឍន៍នានា។ ជាក់ស្តែង នៅប្រទេសកម្ពុជា បរធនបាលកិច្ចត្រូវបានបង្កើតឡើងក្នុងគោលបំណងគ្រប់គ្រងមូលនិធិហិរញ្ញប្បទានឥតសំណង ឬអនុបំណុលដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍ ដើម្បីគាំទ្រវិស័យហិរញ្ញវត្ថុ ហើយបច្ចុប្បន្នមូលនិធិទាំងនោះកំពុងគ្រប់គ្រង និងចាត់ចែងប្រើប្រាស់ដោយគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុមួយចំនួនដើម្បីឆ្លើយតបនឹងការរីកចំរើនទាក់ទងនឹងវិស័យហិរញ្ញវត្ថុ។ ម្យ៉ាងវិញទៀត ច្បាប់នេះ ក៏បានចូលរួមក្នុងការបង្កើនការវិនិយោគក្នុងស្រុក ដែលជាប្រភពនៃការបន្ថែម ចំណូលពន្ធជាតិ ជំរុញការធ្វើពិពិធកម្មហិរញ្ញវត្ថុ ដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជា ផ្តល់លទ្ធភាពដល់ការតាមដាន និងគ្រប់គ្រងលំហូរទុន និងប្រភពទុន លើគ្រប់វិស័យ ដែលកំពុងធ្វើប្រតិបត្តិការក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅទាក់ទាញទំនុកចិត្តបន្ថែមពីដៃគូអភិវឌ្ឍនានា និងចូលរួម

ចំណែកគាំទ្រដល់បទប្បញ្ញត្តិនានានៅកម្ពុជា ដែលបាននិងកំពុងអនុវត្តជាធរមាន។ តួយ៉ាង តថភាពនៃច្បាប់បរធនបាលកិច្ច បានកើតឡើងក្នុងសង្គមកម្ពុជាតាំងពីយូរយារមកហើយ មុនពេលដែលច្បាប់នេះត្រូវបានអនុម័តទៅទៀត។

## ៤. ការសន្និដ្ឋាន

សរុបមក ច្បាប់ស្តីពី បរធនបាលកិច្ច ជាច្បាប់ដែលទាក់ទងនឹងវិស័យហិរញ្ញវត្ថុថ្មីមួយនៅកម្ពុជា ហើយ វិស័យនេះ នឹងរួមចំនែកដល់ការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសង្គមកម្ពុជាឲ្យកាន់តែមានភាពជឿនលឿន ឆ្លើយតបនឹងបរិបទថ្មីៗ នៃវិស័យហិរញ្ញវត្ថុសកលដើម្បីជាការធានា និងទាក់ទាញនូវភាពទុកចិត្តពីដៃគូអភិវឌ្ឍន៍នានា។

មួយវិញទៀត ច្បាប់នេះ អនុញ្ញាតឱ្យរាជរដ្ឋាភិបាលនឹងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យទៅលើប្រភពបរធនបាលកិច្ចទាំងអស់ ដែលបានធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា ដែលត្រូវរៀបចំឡើងក្នុងគោលបំណងគ្រប់គ្រងមូលនិធិហិរញ្ញប្បទានឥតសំណង ឬអនុបំណុល ដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍ ដើម្បីគាំទ្រវិស័យហិរញ្ញវត្ថុ ហើយបច្ចុប្បន្នមូលនិធិទាំងនោះ កំពុងគ្រប់គ្រង និងចាត់ចែងប្រើប្រាស់ដោយគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុមួយចំនួន។ ដោយពិនិត្យឃើញនូវភាពចាំបាច់នៃវិសាលភាពទូលំទូលាយ ក្នុងវិស័យបរធនបាលកិច្ច ដែលមិនត្រឹមតែគ្រប់ដណ្តប់លើ វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុតែប៉ុណ្ណោះទេ វិស័យនេះ មានវិសាលភាពគ្រប់ដណ្តប់លើវិស័យធានារ៉ាប់រង និងសោធន វិស័យអចលនទ្រព្យ វិស័យមូលបត្រ និងវិស័យផ្សេងៗទៀតនៅក្នុងសេដ្ឋកិច្ច និងសង្គមផងដែរ។

គុណប្រយោជន៍នៃច្បាប់បរធនបាលកិច្ចនេះគឺ (១)បង្កើនការវិនិយោគក្នុងស្រុក ដែលប្រភពនៃការបន្ថែមចំណូលពន្ធជាតិ (២)ជំរុញការធ្វើពិពិធកម្មហិរញ្ញវត្ថុ ដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជា និង (៣) ផ្តល់លទ្ធភាពដល់ការតាមដាន និងគ្រប់គ្រងលំហូរទុន និងប្រភពទុនលើគ្រប់វិស័យ ដែលកំពុងធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា សំដៅទាក់ទាញទំនុកចិត្តបន្ថែម ពីដៃគូអភិវឌ្ឍន៍នានា។

# ប្រធានសក្តិ នៅក្នុងបរិបទច្បាប់កម្ពុជា

# ប្រធានសក្តិ នៅក្នុងបរិបទច្បាប់កម្ពុជា

ដោយលោកមេធាវី ផូ សុធាផល*

## ១. សេចក្តីផ្តើម

ការកកើតឡើងនូវករណីឆ្លងរាតត្បាតនៃមេរោគកូវីដ១៩ បាននាំឱ្យផ្លាស់ប្តូរបែបផែននៃការរស់នៅ និងការប្រកបការងាររបស់ប្រជាជននៅលើពិភពលោក រួមមានទាំងការបិទទីក្រុង ឬបិទប្រទេស ការបិទសាលារៀននិងទីតាំងអាជីវកម្មមួយចំនួនដើម្បីជៀសវាងការជួបជុំប្រមូលផ្តុំ ការបិទអាកាសចរណ៍ហោះហើរ ការដាក់ចេញបទបញ្ជាឱ្យស្នាក់នៅតែក្នុងផ្ទះ ការដាក់បម្រាមគោចរណ៍ និងវិធានការណ៍នានាផ្សេងទៀត ដើម្បីទប់ស្កាត់ការសាយភាពនៃមេរោគនេះ។ វិធានការណ៍ទាំងនេះ បានបណ្តាលឱ្យមានការព្យួរអាជីវកម្មមួយចំនួន និងការថយចុះនៃប្រតិបត្តិការអាជីវកម្មជាទូទៅ និងទំនាក់ទំនងពាណិជ្ជកម្ម ជាពិសេសពាណិជ្ជកម្មអន្តរជាតិ ដែលជះឥទ្ធិពលប៉ះពាល់ដល់ការអនុវត្តកិច្ចសន្យា និងការបំពេញកាតព្វកិច្ចរវាងគូភាគី។ អត្ថបទស្រាវជ្រាវនេះ ព្យាយាមស្វែងយល់អំពីបរិបទនៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធទៅនឹងករណីប្រធានសក្តិ និងសិក្សាថាតើភាគីនៃកិច្ចសន្យាអាចអះអាងលើការរាតត្បាតជាសកលនៃមេរោគកូវីដ១៩នេះ ថាជាប្រធានសក្តិ ដើម្បីឱ្យភាគីបានរួចផុត ឬបានព្យួរ ការអនុវត្តកាតព្វកិច្ចបានឬទេ។

## ២. តួសេចក្តី

ពាក្យថា "ប្រធានសក្តិ" ត្រូវគ្នានឹងពាក្យជាភាសាអង់គ្លេសថា "Force Majeure"។ នៅក្នុងបរិបទនៃភាសាអង់គ្លេស ឬប្រព័ន្ធច្បាប់បែបអង់គ្លូសាក់សុង (Common Law) ប្រហែលជាអាចមានបែងចែករវាងពាក្យថា "Force Majeure" និងពាក្យថា "Act of God" ក៏ប៉ុន្តែនៅក្នុងបរិបទនៃច្បាប់កម្ពុជា ហាក់ដូចជាមិនមានការបែងចែកដូច្នេះទេ គឺមានតែពាក្យ "ប្រធានសក្តិ" តែមួយ បើទោះបីជាមានពាក្យថា "ឧបទ្រព" នៅក្នុងវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជ ជួន ណាត ដែលមានន័យប្រហាក់ប្រហែលនឹងពាក្យអង់គ្លេសថា "Act of God"[68]។

* លោកមេធាវី ផូ សុធាផល ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មេធាវី នៃក្រុមមេធាវី សុធាផ សំណាង សុភី និងសហការី និងជាសាស្ត្រាចារ្យ នៃមន្ទីរសារការីនីតិនិវត្តន៍ នៃព្រះរាជាណាចក្រកម្ពុជា។

សន្ទានុក្រមផ្នែករដ្ឋប្បវេណី បានឱ្យនិយមន័យពាក្យថា "ប្រធានសក្តិ"[69] នេះថាជា "ព្រឹត្តិការណ៍ ដែលកើតឡើងក្រៅឆន្ទៈ មិនអាចប៉ាន់ស្មានជាមុន និងមិនអាចជម្នះបាន" ដែលអាចបកប្រែត្រឡប់ទៅភាសាអង់គ្លេសវិញថា "force majeure is an event that is unintended, unpredictable, and insurmountable"។ សន្ទានុក្រមនេះ អាចត្រូវបានចាត់ទុកថាជាឯកសារសំខាន់ ដែលបន្ថែមទៅលើក្រមរដ្ឋប្បវេណី ប៉ុន្តែពុំមានផ្តល់ការពន្យល់គតិយុត្តបន្ថែម ក្រៅអំពីនិយមន័យដ៏ខ្លីខាងលើនេះឡើយ។ ក្រៅពីសន្ទានុក្រមនេះ លិខិតបទដ្ឋានគតិយុត្ត ដែលអនុវត្តលើវិស័យជាក់លាក់មួយចំនួនបានផ្តល់និយមន័យដល់ពាក្យ "ប្រធានសក្តិ" សម្រាប់អនុវត្តក្នុងវិស័យរបស់ខ្លួន។

នៅក្នុងវិស័យសំណង់ ច្បាប់ស្តីពីសំណង់ ដែលត្រូវបានប្រកាសឱ្យប្រើ ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ មានភ្ជាប់ដោយឧបសម្ព័ន្ធជាសន្ទានុក្រម ដែលកំណត់និយមន័យនៃពាក្យថា "ប្រធានសក្តិ" ដូចគ្នាបេះបិទទៅនឹងនិយមន័យដែលចែងនៅក្នុងសន្ទានុក្រមផ្នែករដ្ឋប្បវេណីខាងលើ។

នៅក្នុងបរិបទពន្ធដារ ប្រកាសលេខ ៥០៧ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធប្រថាប់ត្រា បានកំណត់និយមន័យថា "ប្រធានសក្តិ" សំដៅដល់បាតុភូត ឬជាព្រឹត្តិការណ៍ដែលកើតឡើង ដោយមិនដឹងជាមុន មិនអាចប៉ាន់ស្មានជាមុនបាន និងមិនអាចជម្នះបាន ដូចជា គ្រោះធម្មជាតិ (ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី) សង្គ្រាម កុប្បកម្ម អគ្គិភ័យ ឬគ្រោះមហន្តរាយជាយថាហេតុ។

នៅក្នុងវិស័យការងារ ច្បាប់ស្តីពីការងារ មានចែងអំពីករណីប្រធានសក្តិ ប៉ុន្តែពុំមានចែងជានិយមន័យនៃពាក្យនេះឡើយ។ តួយ៉ាង មាត្រា ៧៣ នៃច្បាប់ស្តីពីការងារ ដែលចែង

[68] យោងតាមវចនានុក្រមអង់គ្លេស Concise Oxford Dictionary (10th Edition), ពាក្យថា act of god មានន័យថា an instance of uncontrollable natural forces in operation ដែលប្រែថា ដំណើរនៃកម្លាំងធម្មជាតិដែលកើតមានក្នុងបច្ចុប្បន្ន ដែលមិនអាចគ្រប់គ្រងបាន។ និយមន័យនេះ ស្រដៀងគ្នាទៅនឹងនិយមន័យនៃពាក្យ "ឧបទ្រព" នៅក្នុងវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជ ជួន ណាត ដែលមានន័យថា ចង្រៃ, អពមង្គល, គ្រោះកាច, ភ័យ, អន្តរាយឬភយន្តរាយ ដែលកើតមានក្នុងបច្ចុប្បន្នទាន់ភ្នែក, ហេតុអាក្រក់។ យោងតាមវចនានុក្រមច្បាប់ Black's Law Dictionary (8th Edition), ពាក្យថា act of god មានន័យថា an overwhelming, unpreventable event caused exclusively by forces of nature, such as an earthquake, flood, or tornado ដែលប្រែថា ហេតុដ៏ខ្លាំងក្លា មិនអាចទប់ស្កាត់បាន ដែលកើតឡើងដោយសារកម្លាំងធម្មជាតិសុទ្ធសាធ ដូចជា រញ្ជួយដី ទឹកជំនន់ ឬព្យុះកំបុតត្បូង ជាដើម។

[69] សន្ទានុក្រមផ្នែករដ្ឋប្បវេណី ដកស្រង់ពីសន្ទានុក្រមពាក្យច្បាប់ ខ្មែរ-បារាំង-អង់គ្លេស ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភា ទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅឆ្នាំ២០០៧ ហើយដែលត្រូវបានបោះពុម្ពភ្ជាប់ជាមួយក្រមរដ្ឋប្បវេណី ដោយក្រសួងយុត្តិធម៌។ យោងតាមសន្ទានុក្រមនេះ ពាក្យថា "ប្រធានសក្តិ" ជាពាក្យដែលស្ថិតនៅលេខរៀងទី ១០០ នៃសន្ទានុក្រម ដែលត្រូវគ្នានឹងពាក្យជាភាសាអង់គ្លេសថា "force majeure"។

អនុញ្ញាតឱ្យភាគីនៃកិច្ចសន្យាការងារមានថិរវេលាកំណត់ អាចរំលាយកិច្ចសន្យាមុនកាលកំណត់បាន ក្នុងករណីប្រធានសក្តិ និងមាត្រា៨២ ដែលលើកលែងឱ្យភាគីនៃកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ អាចរំលាយកិច្ចសន្យាដោយពុំចាំបាច់គោរពកាតព្វកិច្ចឱ្យដំណឹងមុនបាន "ក្នុងករណីប្រធានសក្តិ ដែលភាគីម្ខាងមិនអាចគោរពកិច្ចសន្យារហូតតទៅបាន"។ ច្បាប់ស្តីពីការងារបានពន្យល់បន្ថែមអំពីកាលៈទេសៈ ដែលនាំឱ្យភាគីគ្មានលទ្ធភាពបំពេញតាមកិច្ចសន្យា ដែលកំណត់នៅក្នុងមាត្រា ៨២៖

- ចំពោះនិយោជក អលទ្ធភាពក្នុងការគោរពកិច្ចសន្យា មានករណីជាអាទិ៍៖ ការបិទទ្វារសហគ្រាស ដែលរាជការសាធារណៈតម្រូវឱ្យបិទ, មហន្តរាយ "ទឹកជំនន់ រញ្ជួយផែនដី សង្គ្រាម" ដែលបណ្តាលឱ្យអន្តរាយសម្ភារៈ មិនអាចឱ្យបន្តការងារបានអស់រយៈពេលយូរ (មាត្រា ៨៥)។
- ចំពោះនិយោជិត អលទ្ធភាពក្នុងការគោរពកិច្ចសន្យា មានករណីជាអាទិ៍៖ ជំងឺរ៉ាំរ៉ៃរិកលចរិត ភាពពិការជានិច្ច, ការផ្តន្ទាទោសដាក់ពន្ធនាគារ (មាត្រា ៨៦)។

នៅក្នុងក្រមរដ្ឋប្បវេណី ពាក្យ "ប្រធានសក្តិ" ញាំងបញ្ញត្តិពិសេសក្នុងមាត្រាមួយចំនួនដូចជា៖ មាត្រា ១៤៥ (ករណីយកិច្ចទទួលទឹកហូរតាមធម្មជាតិ), មាត្រា ១៧៧ (ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃលទ្ធកម្មដោយសារមហន្តរាយធម្មជាតិ), មាត្រា ២៥១ (សិទ្ធិរំលាយរបស់អ្នកជួលអចិន្ត្រៃយ៍), មាត្រា ២៧១ (ការទទួលបន្ទុកនូវសោហ៊ុយ), មាត្រា ៣៩៩ (បញ្ញត្តិពិសេសអំពីកាតព្វកិច្ចជាប្រាក់), មាត្រា ៤៩៨ (ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដោយសារមហន្តរាយធម្មជាតិ), មាត្រា ៦០៦ (សិទ្ធិរំលាយ និងសិទ្ធិទាមទារឱ្យបន្ថយថ្លៃឈ្នួល នៅក្នុងករណីដែលចំណូលថយចុះ), មាត្រា ៦៧៤ (ការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើ), មាត្រា ៧៥២ (ការទទួលខុសត្រូវចំពោះវត្ថុគ្រោះថ្នាក់), និងមាត្រា ៨២៦ (ការបញ្ជាំបន្ត)។

ក្រៅអំពីបញ្ញត្តិអំពីបញ្ហាជាក់លាក់នៅក្នុងមាត្រាមួយចំនួនដែលលើកឡើងខាងលើ ច្បាប់ផ្តល់សេរីភាពឱ្យភាគីព្រមព្រៀងគ្នាលើខ្លឹមសារនៃកិច្ចសន្យា ដែលអាចរួមបញ្ចូលខចែងអំពីករណីប្រធានសក្តិ និងលក្ខខណ្ឌសម្រាប់ អនុវត្តក្នុងករណីប្រធានសក្តិ។ ប្រសិនបើកិច្ចសន្យាមានចែងនិយមន័យប្រធានសក្តិ និងលក្ខខណ្ឌអនុវត្តនៅក្នុងករណីប្រធានសក្តិ ប្រការដែលចែងនេះនឹងតម្រង់ទិសដល់ភាគីឱ្យធ្វើសកម្មភាពតាមការព្រមព្រៀងដែលខ្លួនបានធ្វើឡើង

ជាស្រេចនេះ។ ក៏ប៉ុន្តែ ប្រសិនបើពុំមានការព្រមព្រៀងគ្នាជាមុន ដែលចែងនៅក្នុងកិច្ចសន្យាអំពីនិយមន័យ និងលក្ខខណ្ឌអនុវត្តនៅក្នុងករណីប្រធានសក្តិទេនោះ បន្ទុកនៃការផ្តល់ភស្តុតាងនឹងស្ថិតក្នុងករណីយកិច្ចរបស់ភាគី ដែលអះអាងអំពីការកើតឡើងនូវព្រឹត្តិការណ៍ប្រធានសក្តិ ដោយត្រូវបញ្ជាក់ឱ្យឃើញថា ឧបសគ្គដែលកើតឡើងហើយបណ្តាលឱ្យភាគីខ្លួនមិនអាចគោរពអនុវត្តកាតព្វកិច្ចបាននោះ ជាព្រឹត្តិការណ៍ដែលកើតឡើងក្រៅឆន្ទៈរបស់ខ្លួន ដែលខ្លួនមិនអាចប៉ាន់ស្មានជាមុន និងមិនអាចជម្នះបាន។ ទោះជាយ៉ាងនេះក្តី ភាគីម្ខាងទៀតក៏នៅតែអាចបដិសេធអំពីការលើកឡើងនូវករណីប្រធានសក្តិនេះ ព្រោះលក្ខខណ្ឌតម្រូវទាំងបីខាងលើនេះពិបាកផ្ទៀងផ្ទាត់យ៉ាងខ្លាំងថាតើ "ឧបទ្រព" ដែលនាំឱ្យភាគីគ្មានលទ្ធភាពអនុវត្តកិច្ចសន្យាបានពិតជាកើតឡើងក្រៅឆន្ទៈ មិនអាចប៉ាន់ស្មានទុក និងមិនអាចជម្នះបានពិតប្រាកដមែនឬទេ។

ចំពោះករណីការរាតត្បាតជាសកលនៃមេរោគកូវីដ១៩ ឬរោគរាតត្បាតផ្សេងៗទៀត ភាគីអាចអះអាងជាករណីប្រធានសក្តិបាន លុះត្រាតែមានការប្រកាសអំពីភាពអាសន្នពីរាជរដ្ឋាភិបាល ឬក្រសួងសុខាភិបាលជាមុនសិន ព្រោះថា មានតែរាជរដ្ឋាភិបាល ឬក្រសួងសុខាភិបាល ទើបមានសមត្ថភាព និងសមត្ថកិច្ច ក្នុងការវាយតម្លៃ និងសន្និដ្ឋានអំពីកម្រិតនៃគ្រោះថ្នាក់ និងផលប៉ះពាល់នៃការរាតត្បាត ដែលការប្រកាសភាពអាសន្ននោះ ប្រហែលជាបង្កើតនូវស្ថានភាព "មិនអាចជម្នះបាន" ចំពោះភាគី។

## ៣. ចុងបញ្ចប់នៃអត្ថបទ ឬ សេចក្តីសន្និដ្ឋាន

ជាទូទៅ ច្បាប់ឬបទប្បញ្ញត្តិពិសេសមួយចំនួន បានឱ្យនិយមន័យពាក្យ "ប្រធានសក្តិ" ថាជាព្រឹត្តិការណ៍ដែលកើតឡើងក្រៅឆន្ទៈរបស់ភាគី ដែលភាគីមិនអាចប៉ាន់ស្មានជាមុន និងមិនអាចជម្នះបាន ឬនិយមន័យដែលមានអត្ថន័យស្រដៀងនេះ។ ក៏ប៉ុន្តែ បទប្បញ្ញត្តិច្បាប់របស់កម្ពុជាដែលគ្របដណ្តប់លើកិច្ចសន្យា មិនបានផ្តល់និយមន័យនិងការពន្យល់ក្បោះក្បាយរួមមួយឱ្យបានទូលំទូលាយ អំពីពាក្យថា "ប្រធានសក្តិ" ឡើយ។ ដូចនេះ គូភាគីមានសេរីភាពក្នុងការកំណត់ព្រមព្រៀងរវាងគ្នានឹងគ្នា អំពីវិសាលភាពនៃប្រធានសក្តិ និងកាតព្វកិច្ចដែលត្រូវអនុវត្ត (ឬមិនចាំបាច់អនុវត្ត) នៅក្នុងករណីកើតមាននូវព្រឹត្តិការណ៍ប្រធានសក្តិ និងអំឡុងពេលនៃប្រធានសក្តិនោះ រួមទាំងករណីដែលកើតមាននូវជំងឺរាតត្បាត ដូចជាមេរោគកូវីដ១៩ និងករណីស្រដៀងនេះផ្សេងទៀត។ បើពុំនោះទេ ភាគីដែលអះអាងអំពីការកើតឡើងនូវករណីប្រធានសក្តិ ត្រូវមានកាតព្វកិច្ចក្នុងការផ្តល់ភស្តុតាង ថាហេតុការណ៍នោះ ពិតប្រាកដជាបំពេញលក្ខខណ្ឌទាំងបី គឺកើតឡើងក្រៅឆន្ទៈ មិនអាចប៉ាន់ស្មានទុក និងមិនអាចជម្នះបាន។

# សកម្មភាពរបស់គណៈមេធាវី

# ១.ទំនាក់ទំនងជាតិ និងអន្តរជាតិ

## ១.១ ទំនាក់ទំនងជាតិ

### លោក លីវ សុវណ្ណា អគ្គលេខាធិការង និងសហការីរួមជាមួយប្រតិភូគណៈមេធាវីប្រចាំខេត្តកំពង់ចាម បានចុះជួបពិភាក្សាការងារ និងពិនិត្យទីតាំងសាងសង់បន្ទប់មេធាវីដាច់ដោយឡែក ក្នុងពន្ធនាគារខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ

នៅថ្ងៃចន្ទ ០៣ កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ៨:៤០នាទីព្រឹក គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយ លោក លីវ សុវណ្ណា អគ្គលេខាធិការងតំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមប្រធានគណៈមេធាវី និង លោកស្រីមេធាវី លឹម ច័ន្ទលីនដា ប្រធាននាយកដ្ឋានរដ្ឋបាលគណៈមេធាវីនិងសហការីរួមជាមួយប្រតិភូគណៈមេធាវីប្រចាំខេត្តកំពង់ចាម បានចុះជួបពិភាក្សាការងារ និងពិនិត្យទីតាំងសាងសង់បន្ទប់មេធាវីដាច់ដោយឡែក ក្នុងពន្ធនាគារខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ។

នៅក្នុងពិធីនោះ ឯកឧត្តម ហ៊ុន ខី ប្រធានពន្ធនាគារ និងសហការី បានចូលរួមក្នុងកិច្ចពិភាក្សា ដោយក្តីរីករាយ និងយោគយល់ ព្រមទាំងបញ្ជាក់យ៉ាងច្បាស់ថា ខាងពន្ធនាគារមានដីទុកសំរាប់សាងសង់បន្ទប់មេធាវីដាច់ដោយឡែកសំរាប់ជូនគណៈមេធាវី ក្នុងការសាងសង់ ៕ កិច្ចពិភាក្សានេះបានបញ្ចប់ដោយបរិយាកាសរីករាយ និងស្និតស្នាលបំផុត។



នៅថ្ងៃព្រហស្បត៍ទី ៦ កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០២០ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីកម្ពុជា បានចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាថ្នាក់ជាតិស្តីពីកិច្ចការពារកុមារក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា ក្រោមអធិបតីភាពឯឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។ សិក្ខាសាលាថ្នាក់ជាតិនេះរៀបចំឡើងដោយអនុលោមតាមលិខិតរបស់ ទីស្តីការ គណៈរដ្ឋមន្ត្រី ដែលអនុញ្ញាតឲ្យអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ(ក.ជ.ក) រៀបចំផ្តួចផ្តើម ធ្វើច្បាប់ ស្តីពីកិច្ចការពារកុមារនៅកម្ពុជា និងមានគោលបំណងដើម្បីស្វែងយល់ពីច្បាប់ និងបទដ្ឋានគតិយុត្ត ដែលមានស្រាប់ និងសិក្សាពីបញ្ហាប្រឈម និងភាពខ្វះចន្លោះក្នុងការអនុវត្តជាក់ស្តែង ព្រមទាំងបទពិសោធន៍និងការអនុវត្តល្អពីភាគី ពាក់ព័ន្ធសំដៅការពារសិទ្ធិនិងឧត្តមប្រយោជន៍របស់កុមារជាចម្បង។




## បេសកកម្មជួបជាមួយប្រធានពន្ធនាគារតាមបណ្តាខេត្ត

ចាប់ពីថ្ងៃទីថ្ងៃចន្ទ ២ រោច ដល់ ៤ រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី១០-១២ ខែកុម្ភៈ ឆ្នាំ២០២០ លោកមេធាវី លីវ សុវណ្ណា អគ្គលេខាធិការរងគណៈមេធាវី និងលោកស្រីមេធាវី លឹម ច័ន្ទលីដា ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក គណៈមេធាវី លោកស្រីមេធាវី សួន ធារី បានចុះបេសកកម្មជួបជាមួយលោកប្រធានពន្ធនាគារតាមប

ណ្ដាខេត្តចំនួន០៧ គឺពន្ធនាគារខេត្តកំពង់ធំពន្ធនាគារខេត្តព្រះវិហារ ពន្ធនាគារខេត្តឧត្ដរមានជ័យ ពន្ធនាគារខេត្តប៉ៃលិន ពន្ធនាគារខេត្តបន្ទាយមានជ័យ ពន្ធនាគារខេត្តពោធិ៍សាត់ និងពន្ធនាគារខេត្តកំពង់ឆ្នាំង ដើម្បីពិភាក្សាអំពីការសាងសង់បន្ទប់មេធាវីសម្រាប់សម្ភាសកូនក្ដីក្នុងពន្ធនាគារ។ កិច្ចពិភាក្សានេះបញ្ចប់ដោយបរិយាកាសរីករាយ និងទទួលលទ្ធផលជាផ្លែផ្កាដោយបានឯកភាពគ្នាក្នុងការសាងសង់បន្ទប់មេធាវីសម្រាប់សំភាសន៍កូនក្ដីក្នុងពន្ធនាគារទាំង៧ពន្ធនាគារ អោយរួចរាល់ក្នុងរយៈពេល០៣ខែខាងមុខនេះ។ សូមថ្លែងអំណរគុណដល់លោកប្រធានពន្ធនាគារ និងមេធាវីប្រតិភូគណៈមេធាវី តាមបណ្ដាខេត្តទាំង៧ខាងលើ ដែលបានសហការជាមួយគណៈមេធាវីយ៉ាងល្អ ក្នុងការចូលរួមចំណែកលើកកម្ពស់វិស័យយុត្តិធម៌ ក្នុងព្រះរាជាណាចក្រកម្ពុជា។

## ការចុះហត្ថលេខាលើអនុស្សារណៈយោគយល់ រវាងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និង សភាពាណិជ្ជកម្មកម្ពុជា

នៅរសៀលថ្ងៃអង្គារ ១០រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ នៅទីស្នាក់ការ អគ្គនាយកដ្ឋានសភាពាណិជ្ជកម្មកម្ពុជា មានជំនួបរវាង គណៈប្រតិភូគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយ ឯកឧត្ដម សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងគណៈប្រតិភូសភាពាណិជ្ជកម្មកម្ពុជា ដឹកនាំដោយអ្នកឧកញ៉ា គិត ម៉េង ប្រធានសភាពាណិជ្ជកម្មកម្ពុជាដើម្បី « ចុះហត្ថលេខាលើអនុស្សារណៈយោគយល់ រវាងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និង សភាពាណិជ្ជកម្មកម្ពុជា»។

គោលបំណងនៃការចុះអនុស្សារណៈយោគយល់នេះ គឺដើម្បីពង្រីកកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរនៅក្នុងវិស័យពាណិជ្ជកម្ម និងសេវាកម្មច្បាប់ ព្រមទាំងផ្លាស់ប្ដូរបទពិសោធន៍ទៅវិញទៅមក។ ជាមួយគ្នានេះផងដែរ អនុស្សារណៈនៃការយោគយល់ (MOU) នឹងរិតចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរ ក្នុងគោលដៅចូលរួមចែករំលែកព័ត៌មានដែលទាក់ទងនឹងការវិវឌ្ឍផ្នែកពាណិជ្ជកម្ម សេវាកម្មច្បាប់ និងចំណេះដឹងបទពិសោធន៍ផ្នែកច្បាប់ ជាពិសេសច្បាប់ទាក់ទងនឹង វិស័យពាណិជ្ជកម្ម។ ពិធីនេះបានបញ្ចប់ដោយបរិយាកាសរីករាយ និងស្និទស្នាលយ៉ាងក្រៃលែង។





## ឯកឧត្តម សួន វិសាល ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំប្រតិភូគណៈមេធាវី ដើម្បីជួបសម្តែងការគួរសមជាមួយ ឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងមន្ត្រីក្រោមឱវាទនៅទីស្តីការក្រសួងទេសចរណ៍

នាព្រឹកថ្ងៃពុធ ១១រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០២០ ឯកឧត្តម សួន វិសាល ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំប្រតិភូគណៈមេធាវី ដើម្បីជួបសម្តែងការគួរសមជាមួយ ឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងមន្ត្រីក្រោមឱវាទនៅទីស្តីការក្រសួងទេសចរណ៍។ នៅក្នុងកិច្ចប្រជុំ

ពិភាក្សានេះ ក្រសួងទេចរណ៍ បានស្នើសុំឱ្យគណៈមេធាវីជួយលើកិច្ចការច្បាប់ដល់ក្រសួង ហើយគណៈមេធាវីនៃព្រះរាជាជាណាចក្រកម្ពុជា បានទទួលយកការស្នើសុំ ដោយចាត់តាំងមេធាវីចំនួន០៣រូប ដើម្បីបំពេញកិច្ចការងារច្បាប់ដល់ក្រសួង។ លើសពីនេះ ក្រសួងទេសចរណ៍ និងគណៈមេធាវីនៃព្រះរាជាជាណាចក្រកម្ពុជា នឹងចុះអនុស្សារណៈនៃការយោគយល់ (MOU) ស្តីពីកិច្ចសហប្រតិបត្តិការ លើវិស័យច្បាប់នេះ នាដើម្បីចុះហត្ថលេខានាពេលអនាគត។ កិច្ចប្រជុំនេះបានបញ្ចប់នៅ ក្រោមបរិយាកាសរីករាយ ស្និទស្នាលរវាងស្ថាប័នទាំងពីរ។






## ឯកឧត្តម សួន វិសាល អញ្ជើញជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តមបណ្ឌិត ជា វ៉ាន់ដេត រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នាទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

រាជធានីភ្នំពេញ៖ នៅរសៀលថ្ងៃព្រហស្បត្តិ៍ ២ រោច ខែចែត្រ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី៩ខែមេសា ឆ្នាំ២០២០ ឯកឧត្តម សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូនៃគណៈមេធាវី អញ្ជើញចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តមបណ្ឌិត ជា វ៉ាន់ដេត រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នាទីស្តីការក្រសួងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

នៅក្នុងការអញ្ជើញ និងពិភាក្សាការងារនេះ ឯកឧត្តម សួន វិសាល បានលើកពីសកម្មភាពការងារ និងសមិទ្ធិផលសំខាន់នានារបស់គណៈមេធាវីសម្រេចបានកន្លងមក។ ជាមួយគ្នានេះផងដែរនៅក្នុងកិច្ចពិភាក្សានេះ ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក៏បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តមបានមានប្រសាសន៍បន្ថែមទៀតថា ដើម្បីឲ្យការងារកាន់តែប្រសិទ្ធិភាពខ្ពស់ និងជាការរួមចំណែកកិច្ចការងារសង្គមក្រសួងនឹងផ្តល់ប្រព័ន្ធទូរស័ព្ទពិសេសមួយខ្សែ(Hotline)តាមការស្នើសុំរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដើម្បីផ្តល់ភាពងាយស្រួលដល់ការទំនាក់ទំនងរបស់ប្រជាជនកម្ពុជាទៅកាន់មេធាវីការពារក្តីជូនជនក្រីក្រ។

ជាទីបញ្ចប់នៃការសម្តែងការគួរសម និងពិភាក្សានេះ ឯកឧត្តមប្រធានគណៈមេធាវីបានថ្លែងអំណរគុណ ដល់ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី ចំពោះការគាំទ្រ និងខិតខំប្រឹងប្រែងរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ការសំណេះសំណាលនេះបានបញ្ចប់ ក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល និងភាតរភាពរវាងស្ថាប័នទាំងពីរ។





## ឯកឧត្តម សួន វិសាល អញ្ជើញជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នាទីស្តីការក្រសួងយុត្តិធម៌

រាជធានីភ្នំពេញ៖ នៅរសៀលថ្ងៃព្រហស្បត្តិ៍ ០៣ រោច ខែចែត្រ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី១០ខែមេសា ឆ្នាំ២០២០ ឯកឧត្តម សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូនៃគណៈមេធាវី អញ្ជើញចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងបានពិភាក្សាការងារមួយចំនួនដូចខាងក្រោម៖

១. កិច្ចសហការក្នុងកម្មវិធីជំនួយផ្នែកច្បាប់ និងការការពារក្តីជូនជនក្រីក្រដោយឥតគិតថ្លៃ

២. ការធ្វើវិសោធនកម្មច្បាប់លក្ខន្តិកៈមេធាវី

៣. ការចូលរួមក្នុងយុទ្ធនាការដោះស្រាយបញ្ហាកកស្ទះសំណុំរឿង និងភាពមិនប្រក្រតីនៅតាមតុលាការ

៤. កិច្ចសហការក្នុងការចងក្រងនិងផ្សព្វផ្សាយសាលក្រម សាលដីកាគំរូ ជាសាធារណៈ

ការសំណេះសំណាលនេះបានបញ្ចប់ ក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល និងភាតរភាពរវាងស្ថាប័នទាំងពីរ។ ជាកិច្ចបញ្ចប់ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានប្រគល់នូវ អាល់កុលលាងសម្អាតដៃមួយចំនួន ជូនគណៈមេធាវីដើម្បីប្រើប្រាស់នៅក្នុងគណៈមេធាវី ក្នុងគោលបំណងចូលរួមទប់ស្កាត់ការរីករាលដាលនូវជំងឺកូវីដ-១៩ ៕





## ១.២ ទំនាក់ទំនងអន្តរជាតិ

### លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីកម្ពុជា បានដឹកនាំគណៈប្រតិភូ ដើម្បីពិភាក្សាការងារជាមួយសហព័ន្ធមេធាវីម៉ាឡេស៊ី

នៅព្រឹកថ្ងៃព្រហស្បតិ៍ ១៥ កើត ខែបុស្ស ឆ្នាំ កុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី ៩ ខែមករា ឆ្នាំ ២០២០ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូទៅប្រទេសម៉ាឡេស៊ី ដើម្បីពិភាក្សាការងារជាមួយ សហព័ន្ធមេធាវីម៉ាឡេស៊ី ដោយផ្តោតលើកិច្ចការងារសំខាន់ៗដែលមានរបៀបវារៈដូចជា៖

- កម្មវិធីបណ្តុះបណ្តាល
- ការផ្លាស់ប្តូរបទពិសោធន៍រវាងមេធាវីកម្ពុជា និងម៉ាឡេស៊ី
- កិច្ចសហប្រតិបត្តិការនាពេលអនាគត

កិច្ចពិភាក្សានោះបានចែករំលែកនូវបទពិសោធន៍ល្អៗ រវាងគណៈមេធាវីទាំងពីររួមមាន ការការពារក្តីជូនជនក្រីក្រ កិច្ចសហការនៃបណ្តាប្រទេសក្នុងតំបន់ និងអនុស្សារណៈផ្សេងៗ។ កិច្ចប្រជុំនេះ បានបញ្ចប់ដោយបរិយាកាស រីករាយ និងស្និទ្ធស្នាលប្រកបដោយភាតរភាព។





## លោកមេធាវី សួន វិសាល និងគណៈប្រតិភូនៃគណៈមេធាវីបានចូលរួមកម្មវិធីច្បាប់ប្រចាំឆ្នាំ ២០២០

កាលពីព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ លោកមេធាវីសួន វិសាល និងគណៈប្រតិភូនៃគណៈមេធាវីបានចូលរួមកម្មវិធីច្បាប់ប្រចាំឆ្នាំ ២០២០ ដែលរៀបចំដោយសហព័ន្ធមេធាវីម៉ាឡេស៊ី។ នៅក្នុងកម្មវិធីនេះផងដែរមានការចូលរួមពីថ្នាក់ដឹកនាំគណៈមេធាវីមកពី បណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ និងបណ្តាប្រទេសជុំវិញពិភពលោក នៅក្នុងកម្មវិធីច្បាប់ប្រចាំឆ្នាំ២០២០ ដែលបានធ្វើឡើងនៅទីក្រុង Putrajaya ប្រទេសម៉ាឡេស៊ី។






**លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីបានអនុញ្ញាតឲ្យលោកស្រីមេធាវី Elizabeth Bennett-Martin ជាមេធាវីនៅប្រទេសកាណាដា និងជាតំណាងរបស់អង្គការមូលនិធិការអប់រំច្បាប់សម្រាប់ស្ត្រីកម្ពុជា**

នៅថ្ងៃច័ន្ទ ០៤រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីបានអនុញ្ញាតឲ្យលោកស្រីមេធាវី

Elizabeth Bennett-Martin ជាមេធាវីនៅប្រទេសកាណាដា និងជាតំណាងរបស់អង្គការមូលនិធិការអប់រំច្បាប់សម្រាប់ស្ត្រីកម្ពុជា និងសហការី ដើម្បីជជែក និងពិភាក្សាការងារ។

នៅក្នុងកិច្ចប្រជុំនោះ លោកស្រី Elizabeth Bennett-Martin បានកោតសរសើរដល់គណៈមេធាវីកម្ពុជាដែលបានរៀបចំការប្រលងប្រណាំងចូលធ្វើមេធាវីប្រកបដោយតម្លាភាព ដែលនៅក្នុងនោះនិស្សិតស្ត្រីដែលក្រីក្រដែលបានទទួលឧត្ដម្ភគ្រាំទ្រពីអង្គការរបស់លោកស្រី បានប្រលងជាប់ចំនួនប្រាំរូបផងដែរ។

នៅក្នុងកិច្ចប្រជុំសម្រេចបាន រួមមាន លោកស្រីមេធាវីនឹងផ្ដល់ការឧត្ដម្ភគាំទ្រដល់និស្សិតស្ត្រីកម្ពុជាក្នុងការធ្វើជាអ្នកហាត់ការ នៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងលោកស្រីមេធាវីនឹងផ្ដល់នូវគ្រូឧទ្ទេសពាក់ព័ន្ធនឹងបច្ចេកទេសនៃការស្រាវជ្រាវ និងសរសេរអត្ថបទច្បាប់ សម្រាប់ធ្វើការបណ្ដុះបណ្ដាលដល់មេធាវីកម្ពុជាផងដែរ។
កិច្ចប្រជុំបានបញ្ចប់ទៅដោយបរិយាកាសរីករាយ។



## លោកមេធាវី សួន វិសាល ជួបប្រជុំជាមួយអតីតប្រធានគណៈមេធាវីនៃរដ្ឋវ៉ាស៊ីនតោន

លោកមេធាវី សួន វិសាល ជួបប្រជុំជាមួយអតីតប្រធានគណៈមេធាវីនៃរដ្ឋវ៉ាស៊ីនតោន

នៅថ្ងៃអង្គារ ៥រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៤ ខែមករា

ឆ្នាំ២០២០ នៅទីស្នាក់ការគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាលោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីបានជួបពិភាក្សាការងារជាមួយលោក William D. Pickett អតីតប្រធានគណៈមេធាវី នៃរដ្ឋវ៉ាស៊ីនតោន និងសហការី។ នៅក្នុងជំនួបនេះលោកប្រធានគណៈមេធាវីបានអនុញ្ញាតឲ្យលោកមេធាវី កុយ នាម អគ្គលេខាធិការគណៈមេធាវី ធ្វើសេចក្ដីសង្ខេបអំពីប្រវត្តិ និងការវិវឌ្ឍន៍ការងាររបស់គណៈមេធាវីកន្លងមក។ បន្ថែមពីលើនេះទៀត លោកប្រធានគណៈមេធាវីក៏បានបង្ហាញនូវតម្រូវការជាក់ស្ដែងដែលគណៈមេធាវីបាន និងកំពុងជួបប្រទះ ហើយលោកក៏បានស្នើសុំទៅលោក William D. Pickett ផ្ដល់នូវជំនួយបច្ចេកទេសមួយចំនួនជាពិសេសលើការផ្ដល់នូវអ្នកជំនាញខាងស្រាវជ្រាវច្បាប់ និងសរសេរអត្ថបទច្បាប់ និងប្រព័ន្ធនិន្នន័យច្បាប់សម្រាប់មេធាវីកម្ពុជាធ្វើការស្រាវជ្រាវផងដែរ។

លោក William D. Pickett បានទទួលយកនូវសំណើររបស់កម្ពុជា ហើយលោកនឹងអញ្ជើញគណៈប្រតិភូ នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាទៅធ្វើទស្សនកិច្ចសិក្សានៅសហរដ្ឋអាមេរិកដើម្បីផ្លាស់ប្ដូរបទពិសោធន៍គ្នាទៅវិញទៅមក។ នាពេលអនាគត គណៈមេធាវីទាំងពីរនឹងចុះអនុស្សារណៈយោគយល់គ្នា ដើម្បីធ្វើកិច្ចសហការគ្នាក្នុងវិស័យច្បាប់ និងបច្ចេកទេស។ កិច្ចប្រជុំបានបញ្ចប់ដោយបរិយាកាសរីករាយ។






## លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីកម្ពុជា បានពិភាក្សាការងារជាមួយឯកឧត្តម ចឹយ វិចិត្ត ឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី

នៅថ្ងៃចន្ទ ០៣ កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២០ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីកម្ពុជា បានពិភាក្សាការងារនិងទទួលទានអាហារថ្ងៃត្រង់ជាមួយឯកឧត្តម ចឹយ វិចិត្ត ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី។ នៅក្នុងការទទួលទានអាហារនេះ លោកប្រធានគណៈមេធាវី និងលោកឯកអគ្គរាជទូតបានផ្តោតការពិភាក្សាយ៉ាងយកចិត្តទុកដាក់ពី "យុទ្ធសាស្រ្ត និងវិធានការចាំបាច់នានាដើម្បីផ្តល់ជំនួយផ្នែកច្បាប់ដល់ពលករខ្មែរដែលធ្វើការនៅប្រទេសម៉ាឡេស៊ី។ "កិច្ចពិភាក្សា និងទទួលទាននេះស្ថិតក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល និងយោគយល់អធ្យាស្រ័យគួរជាទីមោទន។



## លោកមេធាវី គង់ សំអុន និងលោកមេធាវី កែ ប៊ុនធឿន បានចូលរួមប្រជុំសិក្សាស្វែងយល់ពីដំណើរការរបស់មណ្ឌលសេវាកម្មយុត្តិធម៌

នៅរសៀលថ្ងៃចន្ទ ០២រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ២០២០ លោកមេធាវី គង់ សំអុន ប្រធាននាយកដ្ឋាន ស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ និងលោកមេធាវី កែ ប៊ុនធឿន ប្រធាននាយកដ្ឋានទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិបានចូលរួមប្រជុំសិក្សាស្វែងយល់ពីដំណើរការរបស់មណ្ឌលសេវាកម្មយុត្តិធម៌ ដើម្បីជួយលើកកម្ពស់សិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា ជាមួយគណៈមេធាវីជប៉ុននៅសាលាខណ្ឌ សែនសុខ រាជធានីភ្នំពេញ ។



## ឯកឧត្តម សួន វិសាល ប្រធានគណៈមេធាវីកម្ពុជា បានទទួលជួបពិភាក្សាជាមួយសហព័ន្ធមេធាវីជប៉ុន

នៅរសៀលថ្ងៃអង្គារ ០៣រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០២០ ឯកឧត្តម សួន វិសាល ប្រធានគណៈមេធាវីកម្ពុជា បានទទួលជួបពិភាក្សាជាមួយសហព័ន្ធមេធាវីជប៉ុន ប្រព្រឹត្តនៅគណៈមេធាវីកម្ពុជា លើគម្រោង "ការលើកកម្ពស់សិទ្ធិទទួលបានយុត្តិធម៌" ដែលមានរបៀបវារៈដូចខាងក្រោម៖

- គម្រោង និងគោលការណ៍ លើគម្រោងកិច្ចសហប្រតិបត្តិការ

- ពេលវេលាលើការអនុវត្តគម្រោង
- ស្ថានភាពបច្ចុប្បន្នលើសិទ្ធិទទួលបានយុត្តិធម៌ នៅប្រទេសកម្ពុជា
- ការពិភាក្សាលម្អិតទៅលើសកម្មភាពគម្រោង
- សន្និសិទអន្តរជាតិដែលនឹងប្រព្រឹត្តទៅនៅ ខែមិថុនា

នៅក្នុងកិច្ចពិភាក្សានេះ សមភាគីទាំងពីរបានផ្លាស់ប្តូរយោបល់ និងបទពិសោធន៍គ្នាទៅវិញទៅមក លើគម្រោង "ការលើកកម្ពស់សិទ្ធិទទួលបានយុត្តិធម៌" និងការអនុវត្តនៅកម្ពុជាដែលគណៈមេធាវីបានធ្វើកន្លងមក។

ចុងក្រោយនៃកិច្ចពិភាក្សានេះឯកឧត្តមប្រធានគណៈមេធាវី បានឯកភាពទទួលយកសំណើរបស់សហព័ន្ធមេធាវីជប៉ុនដើម្បីយកទៅពិចារណា និងដាក់នៅក្នុងសេចក្តីព្រាងចុះអនុស្សារណៈយោគយល់រវាងគណៈមេធាវីកម្ពុជា និងសហព័ន្ធមេធាវីជប៉ុន ដើម្បីចុះហត្ថលេខានាពេលអនាគត។





## ២. ការផ្សព្វផ្សាយច្បាប់តាមរយៈសិក្ខាសាលា

### សិក្ខាសាលាក្រោមប្រធានបទ" គំនូរឧស្សាហកម្ម និងការអនុវត្តនៅកម្ពុជា និងជប៉ុន"

នៅថ្ងៃអង្គារ ៣កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០២០ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សហការជាមួយ សមាគមកម្មសិទ្ធិបញ្ញាកម្ពុជាបានរៀបចំសិក្ខាសាលាក្រោមប្រធានបទ "គំនូរឧស្សាហកម្ម និងការអនុវត្តនៅកម្ពុជា និងជប៉ុន" ក្រោមអធិបតីភាពឯកឧត្តម ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងប្រធានសមាគមកម្មសិទ្ធិបញ្ញាកម្ពុជាសិក្ខាសាលានេះប្រារព្ធធ្វើឡើងនៅទីស្នាក់ការគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងសិក្ខាសាលានេះ ក៏មានវាគ្មិនកិត្តិយសបានឡើងធ្វើបទបង្ហាញពី យន្តការនៃកិច្ចការពារគំនូរឧស្សាហកម្មក្រោមច្បាប់កម្ពុជា ច្បាប់ស្តីពីការរចនា និងការអនុវត្តនៅប្រទេសជប៉ុន និងនីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្មនៅកម្ពុជា។ ក្រៅអំពីការធ្វើបទបង្ហាញនេះ កម្មវិធីសិក្ខាសាលាក៏មាន នូវកម្មវិធីសំណួរចម្លើយទៅកាន់វាគ្មិនកិត្តិយស ដើម្បីជាការដោះស្រាយចម្ងល់ជាការចែកចាយចំណេះដឹង និងការដកបទពិសោធន៍ឲ្យគ្នាទៅវិញទៅមក។

ចុងបញ្ចប់នៃកម្មវិធី លោកមេធាវី គង់ សំអុន ប្រធាននាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានឡើងថ្លែងចំណាប់អារម្មណ៍បិទកម្មវិធី និងបានបិទបញ្ចប់កម្មវិធីរបស់ខ្លួននៅវេលាម៉ោង ១២ ថ្ងៃត្រង់ នាថ្ងៃដដែលនោះ។



## ៣. ជជែកពីច្បាប់

### លោកមេធាវី គង់ សំអុន អញ្ជើញជាវាគ្មិនកិត្តិយលក្នុងការចែករំលែកចំណេះដឹងច្បាប់ស្តីពី "ការប៉ះពាល់ដល់អនីតិជន និងគ្រួសារ"

លោកមេធាវី គង់ សំអុន ប្រធាននាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ នៃគណៈមេធាវីកម្ពុជា បានអញ្ជើញវាគ្មិនកិត្តិយស ក្នុងកម្មវិធីវិទ្យុសិទ្ធិមនុស្សកម្ពុជា លើប្រធានបទ "ការប៉ះពាល់ដល់អនីតិជននិងគ្រួសារ(១)" ។




### លោកមេធាវី ទៀង វុទ្ធា អញ្ជើញជាវាគ្មិនកិត្តិយលក្នុងការចែករំលែកចំណេះដឹងច្បាប់ក្រោមប្រធានបទ "សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាពពីពិរុទ្ធភាព"



## ៤. កិច្ចប្រជុំបុគ្គលិក

### លោកមេធាវី សួន វិសាល ប្រធាន គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំកិច្ចប្រជុំបុគ្គលិក

នៅព្រឹកថ្ងៃពុធ ១៣រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ នៅទីស្នាក់ការ គណៈមេធាវី ក្រោមអធិបតីភាពលោកមេធាវី សួន វិសាល ប្រធាន គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំកិច្ចប្រជុំបុគ្គលិកដើម្បីត្រួតពិនិត្យការងារ និងដំណើរការរីកចម្រើនក្នុងអង្គភាពដែលមានរបៀបវារៈដូចខាងក្រោម៖

១.បើកកិច្ចប្រជុំ

២.រាយការណ៍សកម្មភាព និងសំនួមពរ

៣.មតិណែនាំនិងដំណោះស្រាយបញ្ហាប្រឈមនានា

៤.ផ្សេងៗ

កិច្ចប្រជុំនេះមានការចូលរួមពីបុគ្គលិកគ្រប់នាយកដ្ឋាន និងបុគ្គលិកការិយាល័យរបស់គណៈមេធាវីគ្រប់ជាន់ថ្នាក់។




## ៥. កិច្ចប្រជុំគណៈកម្មការជំនាញ

### លោកមេធាវី គង់ សំអុន បានដឹកនាំអង្គប្រជុំសម្រាប់គណៈកម្មការ ការស្រាវជ្រាវ និងកំណត់តម្លៃ វគ្គបណ្តុះបណ្តាលមេធាវី

នៅថ្ងៃអង្គារ ៥រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៤ ខែមករា ឆ្នាំ

២០២០ នៅទីស្នាក់ការគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា លោកមេធាវី គង់ សំអុន ប្រធាននាយកដ្ឋាន ស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ បានដឹកនាំអង្គប្រជុំ គណៈកម្មការ ការស្រាវជ្រាវ និងកំណត់តម្លៃវគ្គបណ្តុះបណ្តាលមេធាវី ជំនាញឯកទេសដែលមានរបៀបវារៈដូចជា៖

- ការបែងចែកការងាររបស់គណៈកម្មការ
- ការសិក្សាស្រាវជ្រាវមុខវិជ្ជាដែលត្រូវយកមកបណ្តុះបណ្តាល
- ផ្សេងៗ

កិច្ចប្រជុំនេះ បានបញ្ចប់ទៅដោយបរិយាកាសរីករាយ និងប្រកបដោយផលផ្លែផ្កាគួរជាទីមោទន។




## ៦. ផ្សេងៗ

### ការជួបសំណេះសំណាលស្វែងយល់ពីគណៈមេធាវី និងការចូលប្រកបវិជ្ជាជីវៈមេធាវីនៅទីស្នាក់ការគណៈមេធាវី

នាថ្ងៃព្រហស្បតិ៍ ១៣ កើត ខែមាឃ ឆ្នាំ កុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី ៦ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ៣:00 រសៀល នៅទីស្នាក់ការគណៈមេធាវី លោកមេធាវីសួន វិសាល ប្រធានគណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជា រួមជាមួយលោកមេធាវី លីវ សុវណ្ណា អគ្គលេខាធិការរងនៃគណៈមេធាវីបានអនុញ្ញាតិឲ្យនិស្សិតមកពីសាកលវិទ្យាល័យ សៅអ៊ីសថ៍អេយសៀ មកពីខេត្តសៀមរាប បានជួបសំណេះសំណាលស្វែងយល់ពីគណៈមេធាវី និងការចូលប្រកបវិជ្ជាជីវៈមេធាវី ។





## ពិធីពិធីបិទវគ្គបណ្តុះបណ្តាលវគ្គសុក្រឹតការវគ្គទី៨ មេធាវីចូលប្រកបវិជ្ជាជីវៈមេធាវី

នៅរសៀលថ្ងៃសុក្រ ៦រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០២០ នៅទីស្នាក់ការគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា បានប្រារព្ធពិធីពិធីបិទវគ្គបណ្តុះបណ្តាលវគ្គសុក្រឹតការដល់មេធាវីចូលប្រកបវិជ្ជាជីវៈមេធាវី តាមមាត្រា ៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី វគ្គទី៨ក្រោមអធិបតីភាពលោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងពិធីបិទនេះ ក៏មានការចូលរួមពីលោកមេធាវី យឹម សារីប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី និងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី ព្រមទាំងសិស្សវគ្គសុក្រឹតការវគ្គទី៨ ចំនួន ១០០ នាក់ផងដែរ។ លោកអគ្គលេខាធិការគណៈមេធាវីក៏មានមតិផ្តាំផ្ញើដល់សិស្សមេធាវីទាំងអស់ដែលបញ្ចប់វគ្គសិក្សាថ្ងៃនេះ ចេញទៅប្រកបវិជ្ជាជីវៈប្រកបដោយសីលធម៌ខ្ពស់ និងជាមេធាវីប្រកបដោយវិជ្ជាជីវៈ ដើម្បីចូលរួមលើកស្ទួយវិស័យយុត្តិធម៌ក្នុងសង្គមកម្ពុជា។





## ឯកឧត្តម សួន វិសាល បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយក្នុងការប្រារព្ធខួបគម្រប់ ៨ឆ្នាំ របស់ក្រុមហ៊ុនអែយ៉ារ៉ា

នៅព្រឹកថ្ងៃចន្ទ ១ រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី៩ ខែមីនា ឆ្នាំ២០២០ គណៈប្រតិភូនៃគណៈមេធាវី ដឹកនាំដោយឯកឧត្តម សួន វិសាល ប្រធានគណៈមេធាវី គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយក្នុងការប្រារព្ធខួបគម្រប់ ៨ឆ្នាំ របស់ក្រុមហ៊ុនអែយ៉ារ៉ា ដែលកម្មវិធីនេះបានរៀបចំធ្វើឡើងនៅមជ្ឈមណ្ឌលដឺព្រីមៀ សែនសុខ

រាជធានីភ្នំពេញ។ នៅក្នុងពិធីនោះក៏មានការចូលរួមពីបណ្តាសាខាចែម្នកចាយនានារបស់ក្រុមហ៊ុនអៃយ៉ារ៉ានៅទូទាំងប្រទេសកម្ពុជាផង។




ប្រសាសន៍ណែនាំរបស់លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អំពីការបង្ការការរីករាលដាលនៃមេរោគកូរ៉ូណា (COVID19)

https://www.bakc.org.kh/index.php/km/2753-covid19



## គណៈកម្មការព្រឹត្តិបត្រ

| | |
|---|---|
| ១-ឯកឧត្តម សួន វិសាល | ចាងហ្វាងការផ្សាយ |
| ២-លោកមេធាវី កុយ នាម | និពន្ធនាយក |
| ៣-លោកមេធាវី លីវ សុវណ្ណា | លេខាធិការ |

## នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ

| | |
|---|---|
| ១-លោកមេធាវី គង់ សំអុន | ប្រធាននាយកដ្ឋាន |
| ២-លោកមេធាវី  ឆៀង ខុន្ធា | អនុប្រធាននាយកដ្ឋាន |
| ៣-លោក ឃឹម ច័ន្ទធឿន | អនុប្រធាននាយកដ្ឋាន |
| ៤-លោកមេធាវី វ៉ា សំរិត | ប្រធានការិ. ព្រឹត្តិបត្រ និងបោះពុម្ព |
| ៥-លោកមេធាវី ខន សុខេង | ប្រធានការិ.ស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ |
| ៦-លោក ថា ប៊ុនថៃ | ប្រធានការិ.ព័ត៌មានវិទ្យា |
| ៧-លោក ស្រេង សីហប៊ុននុត | ជំនួយការ ការិ.ព័ត៌មានវិទ្យា |
| ៨-កញ្ញាមេធាវី តាន់ ចរណី | បណ្ណារក្ស |
| ៩-លោកមេធាវី តាន់ អៀម | បណ្ណារក្ស |
| ១០-កញ្ញា វ៉ាត់ លាន | ស្ម័គ្រចិត្ត |
| ១១-លោក វ៉ាត ឋិត្យ | ស្ម័គ្រចិត្ត |

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

លោកមេធាវី សារិន ដេណ្វ៉ា

DFDL

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា